# សៀវភៅឯកសារធនធាន

## ពិសោធន៍ គីមីវិទ្យា និង រូបវិទ្យាសម្រាប់ថ្នាក់រៀនកម្ពុជា

### សៀវភៅគ្រូ

**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)**

**Improved Basic Education in Cambodia Project (IBEC)**





USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION


DEVELOPED BY:
WORLD EDUCATION, INC. 44 FARNSWORTH STREET, BOSTON MA 02210 USA TEL: (1) 617-482-9485, WWW.WORLDED.ORG

IN COLLABORATION WITH:
KAMPUCHEAN ACTION FOR PRIMARY EDUCATION, PO BOX 1621, PHNOM PEN, CAMBODIA, WWW.KAPEKH.ORG

# មាតិកា

***អារម្ភកថា- ការប្រើប្រាស់សៀវភៅនេះ***

***ការទទួលស្គាល់***

***អំពីអ្នកនិពន្ធ***

| មេរៀនទី | ចំណងជើង | ទំព័រ សៀវភៅ ក្រសួង | ទំព័រ |
|---|---|---|---|
| | **ផ្នែកទី ១ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៧** | | |
| **ជំពូកទី ១** | **រូបធាតុ និង ចំណែកថ្នាក់រូបធាតុ** | | |
| 1 | **លក្ខណៈរបស់រូបធាតុ ( ចំណាត់ថ្នាក់រូបធាតុ) – រឹង រាវ និង ឧស្ម័ន** | | |
| | ពិសោធន៍ទី ១ : អង្គធាតុរឹង | 98 | 1 |
| | ពិសោធន៍ទី ២ : អង្គធាតុរាវ | 98 | 1 |
| | ពិសោធន៍ទី ៣ : ឧស្ម័ន -តើអ្វីទៅជាឧស្ម័ន? **ក្រដាសកាសែត និង បន្ទាត់** | 134 | 2 |
| 2 | **ទង្វើឧស្ម័ន** | | |
| | ពិសោធន៍ទី ៤ : ប្រតិកម្មរវាងអាលុយមីញ៉ូម និង អាស៊ីតក្លរីទ្រិច (Al + HCl) | 128 | 3 |
| | ពិសោធន៍ទី ៥ : ប្រតិកម្មរវាងម្សៅមេនំ និង ទឹកខ្មេះ | 137 | 4 |
| | ពិសោធន៍ទី ៦ : តើវាជាអង្គធាតុរាវ ឬ អង្គធាតុរឹង? **លក្ខណៈពិសេសនៃម្សៅពោត** | | 5 |
| | ពិសោធន៍ទី ៧ : តើវាជាអង្គធាតុរឹងឬទេ? **ការចាក់ប៉េងប៉ោង** | | 6 |
| 3 | **អន្តរកម្ម** | | |
| | ពិសោធន៍ទី ៨ : ប្រតិកម្មរវាងទឹកខ្មេះ និង សំបកខ្ចៅ ឬ សំបកស៊ុត | 128 | 7 |
| | ពិសោធន៍ទី ៩ : ស៊ុតនៅក្នុងទឹកខ្មេះ ( អូស្មូស) | | 8 |
| 4 | **លក្ខណៈរូបនៃឧស្ម័ន- ការរីកមាឌនៅពេលត្រូវកំដៅ និង ការដាក់សំពាធ** | | |
| | ពិសោធន៍ទី ១០ : ការកំពិតនៃកំប៉ុង | 120 | 9 |
| | ពិសោធន៍ទី ១១ : ស៊ុតក្នុងដប | | 10 |

| | | | |
|---|---|---|---|
| | ពិសោធន៍ទី ១២ : "ការរុញ និង ការទាញ" ឧទាហរណ៍ចំនួនពីរ | | 11 |
| 5 | **ដង់ស៊ីតេ** | | |
| | ពិសោធន៍ទី ១៣ : ដុំឥដ្ឋ និង ដុំឈើ | 110 | 12 |
| | ពិសោធន៍ទី ១៤ : ភេសជ្ជៈកំប៉ុងមានស្ករតិច និង ភេសជ្ជៈកំប៉ុងធម្មតា | | 13 |
| | ពិសោធន៍ទី ១៥: ដបដាក់ទឹក និង ដបដាក់ទឹកអំបិល | 111 | 13 |
| | ពិសោធន៍ទី ១៦: ដុំទឹកកកលិច | 111 | 14 |
| | ពិសោធន៍ ទី ១៧: ស៊ុតនៅក្នុងទឹក ស៊ុតនៅក្នុងទឹកមានអំបិលល្មម និង ស៊ុតនៅក្នុងទឹកមានអំបិលច្រើន | 111 | 15 |
| | ពិសោធន៍ទិ ១៨ : រលកទឹកក្នុងដប | 111 | 16 |
| **ជំពូកទី២** | **ខ្យល់, ឧស្ម័ន** | | |
| 1 | **តើយើងអាចដឹងថាមានខ្យល់ដោយរបៀបណា?** | | |
| | ពិសោធន៍ទី ១៩ : ប៉េងប៉ោងនៅក្នុងដប | 136 | 18 |
| | ពិសោធន៍ទី ២០ : ដបប្លាស្ទិច និង ទឹកក្ដៅ | | 19 |
| 2 | **អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន $O_2$ និងឧស្ម័នកាបូនិច $CO_2$** | | |
| | ពិសោធន៍ទី ២១ : ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន | 138 | 20 |
| | ពិសោធន៍ទី ២២ : ទង្វើស្ងួលុយស្បៀងទឹកកំបោរថ្លា | | 21 |
| | ពិសោធន៍ទី ២៣ : ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នកាបូនិច | 138 | 21 |
| | ពិសោធទី ២៤ : ការផ្លុំឧស្ម័នកាបូនិច | 138 | 22 |


## ផ្នែកទី ២ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៨


| | | | |
|---|---|---|---|
| **ជំពូកទី១** | **រូបធាតុ អាតូម និង ម៉ូលេគុល** | | |
| 1 | **តារាងខួបនៃធាតុគីមី** | | |
| | ពិសោធន៍ទី ១ : ការបង្ហាញពីតារាងខួប | 104 | 25 |
| | ពិសោធន៍ទី ២ : ការវះថ្មពិល យកដែក (Fe) ស័ង្កសី (Zn) កាបូន (C) និងម៉ង់កាណែសឌីអុកស៊ីត ($MnO_2$) | 108 | 27 |
| | ពិសោធន៍ទី ៣ : ធ្វើតេស្តដែកជាមួយមេដែក | | 28 |
| | ពិសោធន៍ទី ៤ : ប្រតិកម្មរវាងស័ង្កសី និងអាស៊ីតក្លរីឌ្រិច | | 29 |
| | ពិសោធន៍ទី ៥ : ទង្វើ និង ការធ្វើតេស្តឧស្ម័នអុកស៊ីសែន | | 30 |

**ជំពូកទី ២ ប្រតិកម្មគីមី**

| | | |
|---|---|---|
| ពិសោធន៍ទី ៦ : ទង្វើឧស្ម័នអុកស៊ីសែន | | 31 |
| ពិសោធន៍ទី ៧ : ចំហេះកាបូន | 139 | 31 |
| ពិសោធន៍ទី ៨ : ចំហេះអ៊ីដ្រូសែន | 140 | 32 |
| ពិសោធន៍ទី ៩ : ច្បាប់រក្សាម៉ាស | 141 | 33 |

**ជំពូកទី ៣ ល្បាយ**

| | | |
|---|---|---|
| ពិសោធន៍ទី ១០ : លាយកំទិចដែកជាមួយដីខ្សាច់- ធ្វើតេស្តជាមួយនឹងមេដែក | 154 | 35 |
| ពិសោធន៍ទី ១១ : លាយអំបិលជាមួយទឹក | 153 | 35 |
| ពិសោធន៍ទី ១២ : ការញែកល្បាយ | 160 | 36 |
| ពិសោធន៍ទី ១៣ : ការធ្វើគ្រីស្តាល់ស្ករស | 161 | 38 |
| ពិសោធន៍ទី ១៤ : ក្រូម៉ាតូក្រាហ្វីដីស (ពណ៌វិធីដីស) | 163 | 39 |

**ផ្នែកទី ៣ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៩**

**ជំពូកទី១ អុកស៊ីសែន និង អ៊ីដ្រូសែន**

| | | |
|---|---|---|
| ពិសោធន៍ទី ១ : ទង្វើឧស្ម័នអុកស៊ីសែន | | 42 |
| ពិសោធន៍ទី ២ : ចំហេះដែក | 118 | 43 |

1 **ចំហេះ អុកស៊ីតកម្ម - រេដុកម្ម**

| | | |
|---|---|---|
| ពិសោធន៍ទី ៣ : ចំហេះទៀន | | 44 |
| ពិសោធន៍ទី ៤ : អត្តសញ្ញាណកម្មឧស្ម័នកាបូនិច | 124 | 45 |
| ពិសោធន៍ទី ៥ : ទង្វើសូលុយស្យុងទង់ដែងស៊ុលផាតកំហាប់ 1M | | 46 |
| ពិសោធន៍ទី ៦ : អាលុយមីញ៉ូមក្លាយជាទង់ដែង (សម្រាប់គ្រូ) | 126 | 47 |
| ពិសោធន៍ទី ៧ : អាលុយមីញ៉ូមក្លាយជាទង់ដែង | | 48 |
| ពិសោធន៍ទី ៨ : ប្រតិកម្មរវាង អាលុយមីញ៉ូម (Al)និង សូដកាត់(NaOH) ស្រទាប់ទាំងបីរបស់កំប៉ុងភេសជ្ជៈ (ការបង្ហាញរបស់គ្រូ) | 132 | 49 |
| ពិសោធន៍ទី ៩ : ទង្វើឱ្យឃើញពីស្រទាប់ប្លាស្ទិចក្នុងកំប៉ុងភេសជ្ជៈ | | 51 |
| ពិសោធន៍ទី ១០ : ការកាត់កំប៉ុង | 126 | 51 |

2 **អ៊ីដ្រូសែន**

**លក្ខណៈរបស់អ៊ីដ្រូសែន**

ពិសោធន៍ទី ១១ : ប៉េងប៉ោងមានឧស្ម័នអ៊ីដ្រូសែន 135 52

**ជំពូកទី ២ ទឹក និង សូលុយស្យុង**

1 **សូលុយស្យុង**

ពិសោធន៍ទី ១២: ការបង្ហាញពណ៌ 144 54

ពិសោធន៍ទី ១៣: រំលាយអំបិលក្នុងទឹក 155 55

ពិសោធន៍ទី ១៤: កំបោរ និង ទឹក 155 55

**ជំពូកទី ៣ អុកស៊ីត អាស៊ីត និងបាស**

ពិសោធន៍ទី ១៥ : អង្គធាតុចង្អុលពណ៌ 176 57

ពិសោធន៍ទី ១៦ : ប្រតិកម្មអាស៊ីត-បាស : ប្រតិកម្មរវាង NaOH និង HCl 176 58

ពិសោធន៍ទី ១៧ : ប្រតិកម្មអាស៊ីត-បាស : ប្រតិកម្មរវាង សូដ្យូមប៊ីកាបូណាត និងទឹកខ្មេះ 184 59

ពិសោធន៍ទី ១៨ : កំបោរ និង ទឹក ( ប្រើអង្គធាតុចង្អុលពណ៌) 184 61

ពិសោធន៍ទី ១៩ : ចំហេះស្ពាន់ធ័រ និង ការតេស្តវត្តមានស្ពាន់ធ័រឌីអុកស៊ីត 126 62

ពិសោធន៍ទី ២០ : ទធ្វើសូលុយស្យុងស៊ូតកាត់ (NaOH) 5 M 63

ពិសោធន៍ទី ២១ : ការរំលាយ ស៊ូតកាត់ (NaOH) 64

ពិសោធន៍ទី ២២ : ប្រតិកម្មរវាង កាល់ស្យូមកាបូណាត ($CaCO_3$) ជាមួយ អាស៊ីតក្លរីឌ្រិច (HCl) 184 64

**សេចក្តីបន្ថែម**

សេចក្តីបន្ថែមទី ១ បញ្ជីទីកន្លែង និងតម្លៃសំភារៈ និងសារធាតុសម្រាប់ពិសោធន៍វិទ្យាសាស្រ្ត 66

សេចក្តីបន្ថែមទី ២ បញ្ជីតម្លៃ និងចំនួនសំភារៈពិសោធន៍សម្រាប់ការស្នើសុំ 67

សេចក្តីបន្ថែមទី ៣ ផ្លាកសញ្ញាសម្រាប់គ្រូរៀបចំសំភារៈពិសោធន៍ 69

# អារម្ភកថា៖ ការប្រើប្រាស់សៀវភៅនេះ

## គំនិតទូទៅមួយចំនួន

សៀវភៅនេះត្រូវបានអភិវឌ្ឍន៍ឡើងដើម្បីលោកគ្រូ អ្នកគ្រូកម្ពុជាក្នុងការប្រើប្រាស់សៀវភៅវិទ្យាសាស្ត្រជាតិដើម្បីផ្លាស់ប្តូរពីការបង្រៀនមានតែទ្រឹស្តី ទៅជាសកម្មភាពដែលឆ្លុះបញ្ចាំងពីអ្វីដែលគេហៅថាវិទ្យាសាស្ត្រ "អនុវត្តន៏" “hands-on”។ នេះមានន័យថា ការសិក្សាវិទ្យាសាស្ត្រដោយគឺការបង្រៀនពីទ្រឹស្តីមូលដ្ឋានដែលសិស្ស រៀនពីសៀវភៅអត្ថបទ ទៅការសិក្សាបរិបទវិញ។ ការបង្រៀនក្នុងវិធីនេះមានការលំបាកមួយចំនួនដោយសារតែ សៀវភៅអត្ថបទរៀបរាប់អំពីពិសោធន៏ដែលប្រើប្រាស់សំភារៈ និងសារធាតុដែលមិនអាចរកបាននៅកម្ពុជា ហើយនិងកង្វះខាតសំភារៈនៅតាមអនុវិទ្យាល័យងផងដែរ។ ក្នុងការអភិវឌ្ឍន៏សៀវភៅនេះ អ្នកនិពន្ធបានចំនាយពេលយ៉ាងច្រើនក្នុងការរិះរកពិសោធន៏ជាមូលដ្ឋាននៃវិទ្យាសាស្ត្រដែលបានពន្យល់នៅក្នុងសៀវភៅអត្ថបទ ប៉ុន្តែថែមទាំងប្រើនូវសំភារះដែលអាចរកបានទៀតផង។ ឧទាហរណ៏ មានពិសោធន៏មួយចំនួននៅក្នុងសៀវភៅធនធាននេះ បានប្រើប្រាស់ទឹកលាងបង្គន់ជំនួស HCl សុទ្ធដោយសារតែវាមាន HCl ជាធាតុផ្សំចំបងនៅក្នុងទឹកលាងសំអាតមួយនេះ។



ការរៀបរាប់ខាងលើនេះមិនមែនមានន័យថា មិនត្រូវការសំភារៈបែបវិទ្យាសាស្តដូចជា បំពង់សាក ចំពុះប៊ុនសិន ឬឧបករណ៏ដទៃទៀតនោះទេ។ នឹងមានតំរូវការចាំបាច់ ដែលយើងសង្ឃឹមថា សាលានឹងអាចប្រាស័យពីថវិការកម្មវិធីពី រដ្ឋាភិបាល និងម្ចាស់ជំនួយរបស់ទីភ្នាក់ងារ អង្គការអប់រំពិភពលោក (World Education), VVOB និង JICA។ ទោះជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថា តាមរយៈការបញ្ចូលគ្នានៃការប្រើប្រាស់សំភារៈដែលអាចមានក្នុងស្រុក ពិសោធន៏សមស្រប និងថវិកាខាងក្រៅ វានឹងអាចប្រព្រឹត្តទៅបានដោយ ទាំងគ្រូ ទាំងសិស្សពិតជាចង់អនុវត្តវិទ្យាសាស្ត្រមូលដ្ឋាននៅក្នុងថ្នាក់រៀនរបស់ពួកគេពិតមែន។

រាល់ការបង្ហាញដែលបានរៀបរាប់នៅក្នុងអត្ថបទនេះ មានមកពីការរៀបចំសិក្ខាសាលាគីមីសម្រាប់គ្រូៗនៅសហរដ្ឋអាមេរិច។ នេះរួមបញ្ចូលទាំង *វិទ្យាស្ថានអប់រំគីមី (the Institute for Chemical Education)*

*សមាគមគ្រូបង្រៀនវិទ្យាសាស្ត្រជាតិ ក្លិបគ្រូគីមីញ៉ូយក* និងឯកសារយោងដ៏ទៃទៀត។ និស្សិតជំនួយការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញក៏បានជួយសម្រួល និងបន្ថែមពិសោធន៍ផងដែរ។ រាល់ពិសោធន៍នៅក្នុងសៀវភៅធនធាននេះបានសាកល្បងនៅក្នុងប្រទេសកម្ពុជា ដើម្បីធានាថាពិសោធន៍ទាំងនោះពិតជាដំណើរការជាមួយនឹងសំភារៈដែលអាចរកបានទាំងនោះមែន។ គីមីវិទ្យា គឺជាវិទ្យាសាស្ត្រពិតមួយ ហើយពេលដែលសំភារៈមិនពិត តើអ្វីគួរតែកើតឡើងដែលជារឿយៗមិនអាចកើតឡើង។ ការសាកល្បង ពិសោធន៍ទាមទារពេលជាច្រើនថ្ងៃ និងច្រើនសប្តាហ៍នៃការសាកល្បងយ៉ាងល្អិតល្អន់ និងការរៀបឧបករណ៍ឱ្យត្រូវទៅនឹងពិសោធន៍នីមួយៗ។ ដូច្នេះគ្រូបង្រៀនវិទ្យាសាស្ត្រនៅតាមសាលារៀន ដែលប្រើប្រាស់សៀវភៅធនធាននេះគួរតែដឹងពីការគោរពតាមការណែនាំ នៅពេលបង្រៀនពីពិសោធន៍ទាំងនេះ។ បន្ថែមពីនេះ បញ្ជីនៃសំភារៈសំរាប់ពិសោធន៍នីមួយៗ (រួមទាំងម៉ាក ឬឈ្មោះ) គឺមាននៅក្នុងឯកសារបន្ថែម ដែលវាជាឯកសារយោងដ៏សំខាន់សំរាប់លោកគ្រូ អ្នកគ្រូនៅពេលធ្វើសំណើរសុំសំរាប់សាលារៀនរបស់ពួកគាត់។

## អំពីការរៀបចំសៀវភៅនេះ

ពិសោធន៍ដែលបានរៀបរាប់នៅក្នុងអត្ថបទនេះ គឺយោងតាមមាតិកានៃកាលវិភាគរដ្ឋក្នុងសៀវភៅគីមីវិទ្យា និងរូបវិទ្យា។ ពិសោធន៍ជាច្រើនសង្កត់ធ្ងន់ទៅលើ គីមីវិទ្យា ប៉ុន្តែក៏មានមួយចំនួនទាក់ទងនឹងរូបវិទ្យាផងដែរ។ ពិសោធន៍ទាំងអស់ត្រូវបានដាក់ខាងក្រោមចំនងជើងនៃជំពូកដែលបានដកស្រង់ពីសៀវភៅរដ្ឋ។ ដើម្បីជួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការផ្សារភ្ជាប់រវាងពិសោធន៍ទាំងនេះជាមួយនឹងការវិភាគរបស់រដ្ឋ ទំព័រនៃឯកសារក្នុងសៀវភៅរដ្ឋ ក៏ត្រូវបានដាក់បញ្ចូលមកជាមួយពិសោធន៍ផងដែរ។



រាល់ពិសោធន៍នីមួយៗ មានគោលបំណងក្នុងលក្ខណៈមួយ ដែលសិស្សអាចយល់ពីលទ្ធផលនៃការធ្វើពិសោធន៍។ វិធីកំណត់គោលបំណងនេះគឺលើសកំពស់ការគិតចំពោះការសិក្សាវិទ្យាសាស្ត្រអនុវត្តន៍ និងគួរត្រូវបានប្រើសំរាប់គ្រូក្នុងការរៀបចំផែនការបង្រៀន។ ទោះបីជាពិសោធន៍ភាគច្រើន សំរាប់សិស្សធ្វើក៏ដោយ ក៏នៅមានពិសោធន៍មួយចំនួន គឺសំរាប់តែគ្រូបង្ហាញប៉ុននោះពីព្រោះវាអាចគ្រោះថ្នាក់ និងសិស្សពិបាកធ្វើ។ សំនួរគន្លឹះមាននៅខាងចុងពិសោធន៍នីមួយៗសំរាប់ក្នុងការពិភាក្សាជាមួយសិស្សក្នុងការសន្និដ្ឋានពីពិសោធន៍ដើម្បីឱ្យពួកគេយល់ពីគោលការណ៍

ដែលគ្រូបង្រៀន។ បន្ទាប់ពីសំនួរគឺមានការពន្យល់ពីអ្វីដែលនឹងកើតមានឡើងនៅក្នុងពិសោធន៍ និងជាចំលើយរបស់សំនួរខាងដើម។

# ការទទួលស្គាល់

ការអភិវឌ្ឍន៍នៃស្នាដៃនេះ អាចប្រព្រឹត្តទៅបានដោយមានការគាំទ្រយ៉ាងធំធេងពី USAID ដែលផ្តល់ឱ្យតាមរយៈគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា(IBECP) ។ ការជួយជ្រោមជ្រែង និងការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្នុងការរៀបចំសិក្ខាសាលាដែលការបង្ហាញរនេះ គឺជាការសាកល្បងនៅតាមកន្លែង ត្រូវបានទទួកស្គាល់យ៉ាងពេញទំហឹង។ នេះមានរាប់បញ្ចូលទាំង POEs ក្នុងខេត្តកំពង់ចាម ក្រចេះ និងសៀមរាបផងដែរ។ ជំនួសមុខឱ្យអ្នកនិពន្ធ ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិក នៃអង្គការអប់ពិភពលោក និង អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជាចំពោះការខិតខំប្រឹងប្រែងក្នុងជួយរៀបចំសិក្ខាសាលានេះ។

អ្នកនិពន្ធក៏សូមថ្លែងអំណរគុណផងដែរចំពោះជំនួយការទាំងពីរនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បើគ្មានពួកគេទេ នោះសិក្ខាសាលាក៏មិនអាចដំណើរការបានដែរ។ កម្លាំង និងការរីករាយក្នុងការសិក្សា ការងាររៀបចំរាប់ម៉ោង និង ការយកចិត្តទុកដាក់ក្នុងការផ្ទេរចំនេះដឹងទៅដល់ជនជាតិខ្មែរជំនាន់ក្រោយ គឺគួរឱ្យស្ញប់ស្ញែង។ អរគុណច្រើន!!!

អ្នកស្រី **គង់ សុនថាវ៉ា**
**ប្រធានអង្គការ អប់រំពិភពលោក**
ភ្នំពេញ

កញ្ញា ២០១០

# អំពីអ្នកនិពន្ធ

សាស្ត្រាចារ្យ **Myra Hauben** ដែលជាសាស្ត្រាចារ្យគីមីម្នាក់មកពីមហាវិទ្យាល័យ College of Staten Island in នៃសាកលវិទ្យាល័យ *City University of New York* បានស្ម័គ្រចិត្តធ្វើការនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញចាប់តាំងពីឆ្នាំ ២០០៣ កំឡុងពេលវិស្សមកាល និងពេលឈប់សម្រាកពីរឆ្នាំរបស់គាត់។ សិក្ខសាលាស្តីពីការបង្ហាញនិងពិសោធន៍នៅកំឡុងខែកក្កដា និងសីហាបានទាក់ទាញនិស្សិតផ្នែកគីមី ជាច្រើននាក់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយឆ្លងកាត់ការចាប់ឆ្នោតដើម្បីតម្រូវតាមទីកន្លែងរបស់សិក្ខាសាលា ។ (មានការបែងចែកជាក្រុមៗ ដែលនៅក្នុងមួយក្រុមមាននិស្សិត ៤ នាក់ ហើយសិក្ខាសាលានោះបានរៀបចំឡើងនៅពេលរសៀល រយៈពេល ២ សប្តាហ៍។ និស្សិតឆ្នើមមួយត្រូវបានជ្រើសរើស និងហ្វឹកហាត់ដើម្បីជួយក្នុងសិក្ខាសាលានីមួយៗ។ សាស្ត្រចារ្យ Hauben បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគីមី ផ្នែករៀចំការណែនាំ និងការប្រើប្រាស់កំព្យូទ័រក្នុងការបង្រៀន។ គាត់មានចំណង់ចំនូលចិត្តយ៉ាងខ្លាំងក្នុងការអប់រំផ្នែកគីមី ធ្វើជាគ្រូ និងការបង្ហាញក្នុងថ្នាក់របស់គាត់ដោយប្រើប្រាស់សម្ភារៈក្នុងស្រុកងាយៗ។ សាស្ត្រចារ្យ Hauben បាននឹងកំពុងចូលរួមសិក្ខាសាលាបង្រៀនគីមី (នៅសហរដ្ឋអាមេរិច និងប្រទេសដ៏ទៃទៀតជាច្រើន) យ៉ាងទៀងទាត់។ កាលពីបីបួនឆ្នាំកន្លងទៅនេះ សាស្ត្រចារ្យ Hauben និងជំនួយការរបស់គាត់បានរៀបចំសិក្ខាសាលាកន្លះថ្ងៃនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកណ្តាល RTTC (2007) បាត់ដំបង RTTC (2008) និងកំពត PTTC (2009)។ ជំនួយការ ៧ នាក់របស់គាត់បានចូលរួមក្នុងសិក្ខាសាលាទាំងនេះដែលពួកគេបានចំនាយពេលជាច្រើនសប្តាហ៍ក្នុងការស្វែងរកសម្ភារៈ រៀបចំសម្ភារៈ និងសិក្សាពីរបៀបដែលមានប្រសិទ្ធភាពសម្រាប់បង្ហាញសម្ភារៈទាំងនោះ និងរបៀបធ្វើឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការបង្ហាញ។

**ប៉ិល នោរចនាហ្សាស៊ីន** បានបញ្ចប់ការសិក្សាផ្នែកគីមីពិសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមានបំណងសិក្សានៅវិទ្យាស្ថានជាតិអប់រំ (NIE) ដែលវគ្គសិក្សាចាប់ផ្តើមនៅខែតុលា។ នាងជាជំនួយការម្នាក់ក្នុងសិក្ខាសាលាចំនួនពីរនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញចាប់ពីខែ កក្កដា ដល់ដខែសីហា ឆ្នាំ២០០៩។ នាងក៏ជាជំនួយការម្នាក់ផងដែរនៅក្នុងសិក្ខាសាលានៅខេត្តកំពត PTTC ក្នុងឆ្នាំ២០០៩។ នាងសង្ឃឹមថានឹងបានចូលរៀនថ្នាក់អនុបណ្ឌិត និងក្លាយខ្លួនជាគ្រូបង្រៀនម្នាក់ ហើយស្រុកកំណើតរបស់នាងនៅខេត្តក្រចេះ។

**ថន សុភត្រា** ជានិស្សិតឆ្នាំទី ៤ផ្នែកគីមីនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់ជាជំនួយការម្នាក់នៅក្នុងសិក្ខាសាលាចំនួនពីរនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចាប់ពីខែ កក្កដា ដល់ខែសីហា ឆ្នាំ២០០៩។ គាត់ក៏ជាជំនួយការម្នាក់ផងដែរនៅសិក្ខាសាលាខេត្តកំពត PTTC ក្នុងឆ្នាំ ២០០៩។ គាត់ជាប់ចំណាត់ថ្នាក់លេខមួយនៅក្នុងថ្នាក់របស់គាត់នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់សង្ឃឹមថា នឹងបានចូលរៀនថ្នាក់អនុបណ្ឌិត និងក្លាយខ្លួនជាគ្រូបង្រៀនម្នាក់ ហើយស្រុកកំណើតរបស់គាត់នៅខេត្តកំពង់ចាម។

# ផ្នែកទី ១ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៧

## Improved Basic Education in Cambodia Project (IBEC)

WORLD EDUCATION, INC

## មាតិកា


ពិសោធន៍ទី ១ : អង្គធាតុរឹង

ពិសោធន៍ទី ២ : អង្គធាតុរាវ

ពិសោធន៍ទី ៣ : ឧស្ម័ន -តើអ្វីទៅជាឧស្ម័ន? **ក្រដាសកាសែត និង បន្ទាត់**

ពិសោធន៍ទី ៤ : ប្រតិកម្មរវាងអាលុយមីញ៉ូម និង អាស៊ីតក្លរីទ្រិច (Al + HCl)

ពិសោធន៍ទី ៥ : ប្រតិកម្មរវាងម្សៅមេនំ និង ទឹកខ្មេះ

ពិសោធន៍ទី ៦ : តើវាជាអង្គធាតុរាវ ឬ អង្គធាតុរឹង? **លក្ខណៈពិសេសនៃម្សៅពោត**

ពិសោធន៍ទី ៧ : តើវាជាអង្គធាតុរឹងឬទេ? **ការចាក់ប៉េងប៉ោង**

ពិសោធន៍ទី ៨ : ប្រតិកម្មរវាងទឹកខ្មេះ និង សំបកខ្ចៅ ឬ សំបកស៊ុត

ពិសោធន៍ទី ៩ : ស៊ុតនៅក្នុងទឹកខ្មេះ (អូស្មូស)

ពិសោធន៍ទី ១០ : ការកំពិតនៃកំប៉ុង

ពិសោធន៍ទី ១១ : ស៊ុតក្នុងដប

ពិសោធន៍ទី ១២ : "ការរុញ និង ការទាញ" ឧទាហរណ៍ចំនួនពីរ

ពិសោធន៍ទី ១៣ : ដុំឥដ្ឋ និង ដុំឈើ

ពិសោធន៍ទី ១៤ : ភេសជ្ជៈកំប៉ុងមានស្ករតិច និង ភេសជ្ជៈកំប៉ុងធម្មតា

ពិសោធន៍ទី ១៥: ដបដាក់ទឹក និង ដបដាក់ទឹកអំបិល

ពិសោធន៍ទី ១៦: ដុំទឹកកកលិច

ពិសោធន៍ ទី ១៧: ស៊ុតនៅក្នុងទឹក ស៊ុតនៅក្នុងទឹកមានអំបិលល្មម និង ស៊ុតនៅក្នុងទឹកមានអំបិលច្រើន

ពិសោធន៍ទិ ១៨ : រលកទឹកក្នុងដប

ពិសោធន៍ទី ១៩ : ប៉េងប៉ោងនៅក្នុងដប

ពិសោធន៍ទី ២០ : ដបប្លាស្ទិច និង ទឹកក្តៅ

ពិសោធន៍ទី ២១ : ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន

ពិសោធន៍ទី ២២ : ទង្វើសូលុយស្យុងទឹកកំបោរថ្លា

ពិសោធន៍ទី ២៣ : ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នកាបូនិច

ពិសោធទី ២៤ : ការផ្លុំឧស្ម័នកាបូនិច

# ជំពូកទី ១

# លក្ខណៈនៃរូបធាតុ : រឹង រាវ និង ឧស្ម័ន

## លក្ខណៈរបស់រូបធាតុ

**ពិសោធន៍ទី ១ : អង្គធាតុរឹង** សៀវភៅសិស្សថ្មី ទំព័រ ៩៨

សៀវភៅសិស្សថ្មី ទំព័រ ៩៨

គោលបំណង : សិស្សអាចសិស្សអាចសំគាល់ពីលក្ខណៈរបស់អង្គធាតុរឹង ។

សំភារៈ និងសារធាតុ : - ដុំឥដ្ឋមួយដុំ ឬ ដុំឈើមួយដុំ
- កែវតូចមួយ
- កែវធំមួយ

ដំណើរការពិសោធន៍ : ១- ដាក់ដុំឥដ្ឋមួយនៅក្នុងកែវតូចមួយ ហើយមើលរូបរាងរបស់ឥដ្ឋ ។
២- ដាក់ដុំឥដ្ឋដដែលនោះនៅក្នុងកែវមួយទៀតដែលធំជាងមុន
បន្ទាប់មកពិនិត្យមើលរូបរាងរបស់ដុំឥដ្ឋនោះម្តងទៀត ។

សំនួរគន្លឹះ : តើអង្គធាតុរឹងមានរាងប្រែប្រួលដែរឬទេនៅពេលយើងផ្ទេរវាពីកន្លែងមួយទៅកន្លែងមួយ?

អង្កេត : រូបរាងរបស់អង្គធាតុរឹងមិនប្រែប្រួលទេ ។ វាមានរាងកំនត់ច្បាស់លាស់ ។




**ពិសោធន៍ទី ២: អង្គធាតុរាវ** សៀវភៅសិស្សថ្មី ទំព័រ ៩៨

សៀវភៅសិស្សថ្មី ទំព័រ ៩៨

គោលបំណង : សិស្សអាចសំគាល់ពីលក្ខណៈរបស់អង្គធាតុរាវ ។

សំភារៈ និងសារធាតុ : - ពែងតូចមួយ
- ពែងធំមួយដែលមានរូបរាងខុសពីពែងតូច
- ទឹក

ដំណើរការពិសោធន៍: ១-ចាក់ទឹកល្មមសមគួរទៅក្នុងពែងតូចបន្ទាប់មកពិនិត្យមើលរូបរាងរបស់ទឹក ។

២- ចាក់ទឹកពីពែងតូចនោះទៅក្នុងពែងធំ ហើយពិនិត្យមើលរូបរាងនៃ ទឹក ម្តងទៀត។

៣- ចាក់ទឹកពីពែងធំត្រលប់ចូលទៅក្នុងកែវទីមួយវិញ។

៤- ចាក់ទឹកពីដបធំត្រលប់ចូលទៅក្នុងដបតូចទីមួយវិញ។

សំនួរគន្លឹះ : តើអង្គធាតុរាវមានរាងដូចម្តេចពេលយើងផ្ទេរវាពីកន្លែងមួយទៅកន្លែងមួយ?

អង្កេត : អង្គធាតុរាវមានរូបរាងដូចវត្ថុដែលផ្ទុកវា ប៉ុន្តែមាឌរបស់វាមិនប្រែប្រួលទេ។




**ពិសោធន៍ទី ៣: ឧស្ម័ន- តើអ្វីទៅជាឧស្ម័ន?** សៀវភៅសិស្សថ្មី ទំព័រ ១៣៤

សៀវភៅសិស្សថ្មី ទំព័រ ១៣៤

គោលបំណង : សិស្សអាចសំគាល់ពីសំពាធខ្យល់ដែលនៅជុំវិញខ្លួលយើង។

សំភារៈ និងសារធាតុ :
- ក្រដាស់កាសែត
- បន្ទះឈើត្រង់រាបស្មើមួយ រឺ បន្ទាត់ឈើមួយ

ដំណើរការពិសោធន៍: ១- ដាក់ក្រដាស់កាសែតគ្របពីលើបន្ទាត់ឈើនៅលើតុ ដោយទាញបន្ទាត់ឈើ ចេញពីគែមតុប្រមាណជា ២-៣ cm ។

២- វាយបន្ទះឈើអោយរហ័សដោយកាប់របៀបការ៉ាតេ

អង្កេត : ក្រដាស់មិនហើរ ឬហើប ចេញពីតុទេ។

សំនួរគន្លឹះ : ហេតុអ្វីបានជាក្រដាសមិនហើរចេញពីតុ?

ការពន្យល់ : ក្រដាស់មិនហើរ ឬហើបចេញពីតុ ពីព្រោះតែសំពាធនៃខ្យល់។



## ឧទ្ទ័ឧស្ម័ន

**ពិសោធន៍ទី ៤: ប្រតិកម្មរវាងអាលុយមីញ៉ូម និង អាស៊ីតក្លរីទ្រិច ( Al + HCl )**

គោលបំណង : សិស្សអាចផលិតឧស្ម័នតាមរយៈប្រតិកម្មគីមី ។ សៀវភៅសិស្សថ្មី ទំព័រ ១២៨

សៀវភៅសិស្សថ្មី ទំព័រ ១២៨

សំភារៈ និងសារធាតុ :
- បំណែកតូចៗនៃក្រដាសអាលុយមីញ៉ូម
- HCl (ទឹកលាងបង្គន់)
- បំពង់សាក ជើងទម្របំពង់សាក និងដង្កៀបបំពង់សាក
- ប៉េងប៉ោងតូច

ដំណើរការពិសោធន៍:

១- ដាក់បំណែកក្រដាសអាលុយមីញ៉ូមទៅក្នុងបំពង់សាកមួយដែលដាក់នៅលើជើងទំរបំពង់សាក ។

២- ចាក់បន្ថែម HCl (ទឹកលាងបង្គន់) ពីលើ Al ដែលមាននៅក្នុងបំពង់ សាក ។

៣- ភ្ជាប់ប៉េងប៉ោងមួយនៅលើមាត់បំពង់សាក ។

អង្កេត : មានពពុះកកើតឡើងនៅក្នុងសូលុយស្យុង ហើយប៉េងប៉ោងឡើងប៉ោង ។

សំនួរគន្លឹះ : ហេតុអ្វីបានជាប៉េងប៉ោងឡើងប៉ោង?

ការពន្យល់ : ពពុះទាំងនេះជាឧស្ម័នដែលកកើតឡើងដោយសារប្រតិកម្មរវាង Al និង HCl ហើយឧស្មន័នេះ ជាមូលហេតុដែលធ្វើអោយប៉េងប៉ោងឡើងប៉ោង ។



## ពិសោធន៍ទី ៥ : ប្រតិកម្មរវាងម្សៅមេនំ និង ទឹកខ្មេះ

សៀវភៅសិស្សថ្មី ទំព័រ ១៣៧

គោលបំណង : សិស្សអាចសំគាល់ពីឧស្ម័នដែលបង្កើតបានប្រតិកម្មគីមី និងប្រៀបធៀបពីដង់ស៊ីតេរបស់វា ។

សំភារៈ និងសារធាតុ :
- ដបទឹកសុទ្ធទទេមួយដែលគ្មានគំរប
- ទឹកខ្មេះ
- មេនំ ($NaHCO_3$)
- ប៉េងប៉ោងតូចពីរ

ដំណើរការពិសោធន៍ :

១- ចាក់ទឹកទៅក្នុងដបប្រមាណជាមួយភាគបួននៃដប

២- បន្ថែមទឹកខ្មេះដែលមានបរិមាណស្មើនឹងទឹកចូលទៅក្នុងដប ។

៣- ទាញប៉េងប៉ោងអោយយឺត ហើយផ្លុំខ្យល់ចូល បន្ទាប់មកបន្ធូរអោយខ្យល់ចេញវិញ ។ ដាក់ ១ រឺ ២ ស្លាបព្រានៃម្សៅមេនំទៅក្នុងប៉េងប៉ោងនោះ ។

៤- មួលកប៉េងប៉ោងដើម្បីជៀសវាងការកំពប់ម្សៅចេញ ហើយដាក់ប៉េងប៉ោងនោះគ្របពីលើមាត់ដប ។

៥- ពន្លាប៉េងប៉ោង ហើយចាក់ម្សៅមេនំចូលនៅក្នុងទឹកខ្មេះ ។

៦- នៅពេលដែលប៉េងប៉ោងឡើងធំ ត្រូវដកវាចេញហើយគួចមាត់វា ។

៧- ផ្លុំខ្យល់ចូលប៉េងប៉ោងមួយទៀតរហូតដល់វាមានទំហំប៉ុនប៉េងប៉ោងទី១ ហើយគួចមាត់វា ។

៨- កាន់ប៉េងប៉ោងទី២ អោយមានកំពស់ស្មើគ្នា- ដៃផ្កាប់ចុះក្រោមរួចទំលាក់ប៉េងប៉ោងទាំងពីរទៅលើកំរាល ។

សំនួរគន្លឹះ : តើមានអ្វីនៅក្នុងប៉េងប៉ោង បន្ទាប់ពីប្រតិកម្ម? តើអ្នកអាចសន្និដ្ឋានសង់ស៊ីតេរបស់ដូចម្តេចបើធៀបនឹងខ្យល់?

អង្កេត : ប៉េងប៉ោងដែលមានផ្ទុកឧស្មន័(កាបូនឌីអុកស៊ីត)បានមកពីប្រតិកម្មរវាងទឹកខ្មេះជាមួយមេនំធ្លាក់មកលើដីមុន ។

ការពន្យល់ : ឧស្មន័កាបូនឌីអុកស៊ីត មានដង់ស៊ីតេធំជាងខ្យល់ ។



## រូបភាព តំណាងឱ្យ អង្គធាតុរឹង អង្គធាតុរាវ និង ឧស្ម័ន

តារាងនៃលក្ខណៈរបស់អង្គធាតុរឹង អង្គធាតុរាវ និង ឧស្ម័ន

| លក្ខណៈ \ រូបធាតុ | អង្គធាតុរឹង | អង្គធាតុរាវ | ឧស្ម័ន |
|---|---|---|---|
| **រូបរាង** | កំណត់ | ដូចវត្ថុដែលផ្ទុកវា | មិនកំណត់ |
| **ដង់ស៊ីតេ** | ធំ | មធ្យម | តូច |
| **មាឌ** | កំណត់ | កំណត់ | មិនកំណត់ |
| **ទំរង់នៃអាតូម រឺភាគល្អិត** |  |  |  |
| **ភាពអាចហូរបាន** | មិនអាច | អាច | អាច |
| **ភាពអាចបំណែនបាន** | មិនអាច | មិនអាច | អាច |

*ចូរប្រើប្រាស់តារាងនេះដើម្បីពន្យល់ និងសរុបពីការអង្កេតរបស់សិស្សពីការពិសោធខាងលើនេះ ។*

## ពិសោធន៍ទី ៦: តើវាជាអង្គធាតុរាវ រឺ អង្គធាតុរឹង? លក្ខណៈពិសេសនៃម្សៅពោត

គោលបំណង : សិស្សអាចសំគាល់ពីលក្ខណៈពិសេសរបស់ម្សៅពោត ។

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

សំភារៈ និងសារធាតុ :
- ចានជ័រសំរាប់ដាក់ម្សៅពោត
- ម្សៅពោត
- ទឹក

ដំណើរការពិសោធន៍ :

១- លាយបរិមាណស្មើគ្នារវាងម្សៅពោត និង ទឹករហូតដល់ដូចភក់ ។

២.- តេស្តលក្ខណៈ

- ពួតជា "ដុំបាល់" ហើយបើកដៃរបស់អ្នក ( អង្កេតៈ ហូរដូចអង្គធាតុរាវ )
- ចុចម្រាមដៃទៅក្នុងល្បាយ ( អង្កេតៈ ចូលយ៉ាងស្រួល )

- ដាល់ល្បាយម្សៅពោត (អង្កេត: មានអារម្មណ៍ថាមានកំលាំងទប់មកវិញ)




<u>សំនួរគន្លឹះ</u> : តើអ្នកពន្យល់ពីលក្ខណៈរបស់ម្សៅពោតយ៉ាងដូចម្តេច?

<u>ការពន្យល់</u> : ពេលអ្នកដាក់ម្រាមដៃទៅក្នុងម្សៅគឺងាយផុងចូលប៉ុន្តែបើអ្នកដាល់វាហាក់ដូចជាមានកំលាំងទប់នឹងដៃរបស់អ្នក។

**<u>ពិសោធន៍ទី ៧:</u> <u>តើវាជាអង្គធាតុរឹង រឺទេ? ការចាក់ប៉េងប៉ោង</u>**

<u>គោលបំណង</u> : សិស្សអាចសំគាល់ពីលក្ខណៈរបស់ប៉េងប៉ោង។

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

<u>សំភារ: និងសារធាតុ</u> :
- ប៉េងប៉ោងមួយ
- ចង្កឹះឬស្សីស្រួចសំរាប់ចាក់ប៉េងប៉ោង

<u>ដំណើរការពិសោធន៍</u> : ១- ផ្លុំប៉េងប៉ោង

២-យកឈើចាក់ពីគួថ ឬក្បាលរបស់ប៉េងប៉ោងដែលជាកន្លែងមានកៅស៊ូក្រាស់ហើយត្បារវាចេញទៅជិតកន្លែងដែលមានចំណង។ ប្រើការត្បារបង្វិលនៅពេលដែលអ្នករុញឈើចូល។

<u>អង្កេត</u> : ប៉េងប៉ោងមិនបែកទេ។

<u>សំនួរគន្លឹះ</u> :តើប៉េងប៉ោងមានលក្ខណៈដូចម្តេចខ្លះ?

<u>ការពន្យល់</u> : ធម្មជាតិនៃកៅស៊ូ គឺ ជាប៉ូលីមែដែលមានលក្ខណៈអាចបត់បែនបាន និង មានរន្ធតូចល្អិតៗជាច្រើន។ ហេតុដូចនេះ ឈើអាចចាក់ចូលតាមរន្ធទាំងនោះបាន។



## អន្តរកម្ម

**ពិសោធន៍ទី ៨ : ប្រតិកម្មរវាងទឹកខ្មេះ និង សំបកខ្យង ឬ សំបកស៊ុត** សៀវភៅសិស្សថ្មី ទំព័រ ១២៨

សៀវភៅសិស្សថ្មី ទំព័រ ១២៨

គោលបំណង : សិស្សអាចពណ៌នាពីប្រតិកម្មគីមីរវាងទឹកខ្មេះ និងសំបកខ្យង ឬសំបកស៊ុត។

សំភារៈ និងសារធាតុ :
- បំពង់សាក ជើងទំរបំពង់សាក និង ដង្កៀបបំពង់សាក
- ទឹកខ្មេះ
- សំបកខ្យង រឺ សំបកស៊ុត
- ប៉េងប៉ោងតូចមួយ

ដំណើរការពិសោធន៍ :

១- បំបែកសំបកខ្យង រឺ សំបកស៊ុតទៅជាបំណែកតូចៗ

២- ដាក់បំណែកនៃសំបកខ្យងខ្លះៗ រឺ សំបកស៊ុតខ្លះៗទៅក្នុងបំពង់សាក

៣- ចាក់ទឹកខ្មេះប្រមាណជាមួយភាគបីទៅលើសំបកទាំងនោះក្នុងបំពង់សាក

៤- ភ្ជាប់ប៉េងប៉ោងមួយទៅលើមាត់បំពង់សាក

អង្កេត : ពពុះត្រូវបានលេចឡើង ហើយប៉េងប៉ោងក៏ប៉ោងឡើង។

សំនួរគន្លឹះ : ហេតុអ្វីបានជាប៉េងប៉ោងឡើងប៉ោង?

ការពន្យល់ : ពពុះជាឧស្ម័នដែលត្រូវបានបង្កើតឡើងដោយសារប្រតិកម្មរវាងសំបកស៊ុត និង ទឹកខ្មេះ ($CH_3COOH$) ហើយ ឧស្ម័ននេះជាមូលហេតុដែលធ្វើឱ្យប៉េងប៉ោងឡើងប៉ោង។



## ពិសោធន៍ទី ៩ : ស៊ុតនៅក្នុងទឹកខ្មេះ ( អុស្មូស)

គោលបំណង : សិស្សអាចពណ៌នាអំពីបាតុភូតអូស្មូសដែលកើតមាន ពេលយើដាក់ស៊ុតទៅក្នុងទឹកខ្មេះ ។

សំភារៈ និងសារធាតុ :
- ស៊ុតឆៅ
- ទឹកខ្មេះ
- ដបសំរាប់ដាក់ស៊ុត និងទឹកខ្មេះ

មិនមានឯកសាយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

ដំណើរការពិសោធន៍ ១ :
១- ដាក់ស៊ុតមួយទៅក្នុងដប ហើយចាក់ទឹកខ្មេះអោយលិចស៊ុតនោះ ។
២- បង្វិលប្រែស៊ុតចុះឡើងថ្នមៗនៅថ្ងៃបន្ទាប់ ។
៣- យកស៊ុតចេញហើយអង្អែលថ្នមៗ ដើម្បីជួយយកសំបកដែល នៅសល់ចេញ ។ ( វាត្រូវចំណាយពេលពីរទៅបីថ្ងៃដើម្បីអោយស៊ុតនៅសល់តែភ្នាស់ខាងក្នុងដូចនេះ ទឹកខ្មេះអាចមានអំពើបន្តជាមួយស៊ុតបាន) ។

អង្កេត : ស៊ុតឡើងធំជាងមុនក្រោយពេលសំបកបានបាត់អស់ ហើយស៊ុតមានប្រតិកម្មជាមួយទឹកខ្មេះ ។

សំនួរគន្លឹះ : តើមានអ្វីខ្លះកើតឡើងចំពោះទំហំរបស់ស៊ុតនៅក្នុងទឹកខ្មេះ? ក្នុងទឹកស្ករ?

ការពន្យល់ : នៅក្នុងទឹកខ្មេះមានទឹកច្រើនជាងនៅក្នុងស៊ុត ហើយទឹកអាចចូលទៅក្នុងស៊ុតតាមរយះស្រទាប់ស្តើងដែលនៅព័ទ្ធផ្នែកខាងក្រៅនៃស៊ុត ។ ដំណើរការនេះគឺត្រូវបាន គេហៅថា **អូស្មូស** ។

ដំណើរការពិសោធន៍ ២ : ធ្វើអោយស៊ុតតូចជាងមុន ( ច្រាសអូស្មូស)
- ដាក់ស៊ុតដែលឡើងធំនោះ ទៅក្នុងសូលលុយស្យុងស្ករដែលខាប់ខ្លាំង ( ស្ករច្រើនហើយទឹកតិច) រយះពីរ រឺ បីថ្ងៃ ។




ស៊ុតក្នុងទឹកខ្មេះ (ពេលចាប់ផ្តើម) | ស៊ុតក្នុងទឹកខ្មេះ (ពេលបានពីរ បីថ្ងៃបន្ទាប់) | ស៊ុតក្នុងទឹកខ្មេះ (ក្រោយពេលដាក់ក្នុងទឹកស្ករ)

## លក្ខណៈរូបនៃឧស្ម័ន

**ពិសោធន៍ទី ១០ :** **ការកំពិតនៃកំប៉ុង** សៀវភៅសិស្សថ្មី ទំព័រ ១២០, ១២១

គោលបំណង : សិស្សអាចសំគាល់ពីលក្ខណៈរបស់ឧស្ម័នពេលក្តៅ និងត្រជាក់ដែលប៉ះពាល់ទៅដល់សំពាធឧស្ម័ន

សំភារៈ និងសារធាតុ :
- ចានដែកធំមួយ ឬ ចានជ័រធំមួយ
- ទឹក
- កំប៉ុងភេសជ្ជៈមួយ
- ដង្កៀបសំរាប់កៀបកំប៉ុង
- ចង្កៀងអាល់កុល
- ឈើគូស

ដំណើរការពិសោធន៍ :

១- ចាក់ទឹកទៅក្នុងកំប៉ុងប្រហែល 1cm រួចកំដៅវារហូតមានចំហាយទឹកភាយឡើង រយៈពេលប្រហែលជា ៣០ វិនាទី ។

២- ផ្កាប់កំប៉ុងយ៉ាងរហ័ស (យកដង្កៀបកាន់ផ្នែកបាតនៃកំប៉ុង) ក្រឡាប់ចូលទៅក្នុងចានជ័រធំ ។

អង្កេត : កំប៉ុងកំពិតជាមួយសំលេងផ្ទុះ (ផប់)

សំនួរគន្លឹះ : ហេតុអ្វីបានជាកំប៉ុងកំពិត?

ការពន្យល់ : ការកំដៅធ្វើអោយខ្យល់ហើរចេញក្រៅកំប៉ុង ។ ការចុះត្រជាក់ ជាមូលហេតុធ្វើឱ្យ ខ្យល់ដែលបានចេញពីកំប៉ុងរួមគ្នាជាមួយសំពាធខ្យល់ខាងក្រៅផ្ទប់ធ្វើឱ្យកំប៉ុងកំពិត ។



**ពិសោធន៍ទី ១១ :** **ស៊ុតក្នុងដប**

គោលបំណង : សិស្សអាចសំគាល់ពីលក្ខណៈរបស់ឧស្ម័នពេលក្តៅ និងត្រជាក់ដែលប៉ះពាល់ទៅដល់សំពាធឧស្ម័ន។

សំភារៈ និងសារធាតុ :
- កែវអ៊ែរឡែនចំនុះ (500 mL)
- ក្រដាស
- ឈើគូស រឺដែកកេស
- ស៊ុតឆ្អិនមួយ
- កន្ត្រៃ

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

ដំណើរការពិសោធន៍ :
១- បកសំបកស៊ុតចេញ
២- ដុតក្រដាស(ដូចរូប)ហើយដាក់វាក្នុងកែវអ៊ែរឡែន
៣- ភ្លាមៗ នោះ ដាក់ស៊ុតដែលបករួចទៅលើមាត់នៃកែវអ៊ែរឡែន(500ml)

អង្កេត : ស៊ុតត្រូវបានបឺតចូលទៅក្នុងកែវអ៊ែរឡែន។

សំនួរគន្លឹះ : ហេតុអ្វីបានជាស៊ុតអាចធ្លាក់ចូលក្នុងដបបាន? តើត្រូវធ្វើដូចម្តេចដើម្បីយកស៊ុតចេញវិញបាន?

ការពន្យល់ទី១ : ខ្យល់ចេញពីដបនៅពេលត្រូវបានគេកំដៅដោយការដុតក្រដាស។ ស៊ុតដែលដាក់លើមាត់កែវរារាំងខ្យល់ដែលចេញពីកែវចូលមកក្នុងហើយជាហេតុធ្វើ អោយសំពាធខ្យល់ខាងក្រៅរុញច្រានស៊ុតចូលទៅក្នុងដប។

ការពន្យល់ទី២ : ដើម្បីយកស៊ុតចេញ (លាងសំអាតផេះចេញជាមុនសិន) ក្រឡាប់កែវអ៊ែរឡែនចុះក្រោម ដូចនេះស៊ុតគឺនៅនឹងមាត់កែវ។ យកមាត់ខ្ទប់ជុំវិញមាត់កែវហើយ ផ្លុំឱ្យខ្លាំង រយះពេល ១៥-២០ វិនាទីចាំចាប់ស៊ុត!



**ពិសោធន៍ទី ១២ :** **ការរុញ និង ការទាញ**

គោលបំណង : សិស្សអាចបកស្រាយលក្ខណៈសំខាន់មួយចំនួនរបស់សំពាធបរិយាកាសដែលនៅជុំវិញខ្លួនយើង

សំភារៈ និងសារធាតុ :
- ដបកែវមួយ
- ក្រដាសរឹងមួយ
- ទឹក

មិនមានឯកសាយោងនៅក្នុងសៀវភៅ អត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

ដំណើរការពិសោធន៍ :
១- បំពេញទឹកចូលទៅក្នុងដបរហូតពេញ
២- ដាក់ក្រដាសរឹងនៅលើមាត់ដប
៣- ដាក់ដៃរបស់អ្នកនៅលើក្រដាសហើយផ្កាប់ដបចុះក្រោមយ៉ាងរហ័ស

អង្កេត : ក្រដាសរក្សាទឹកនោះក្នុងដប

សំនួរគន្លឹះ : តើមានអ្វីទប់ក្រដាស? ហេតុអ្វីបានជាក្រដាសមិនធ្លាក់ចុះក្រោម?

ការពន្យល់ : សំពាធខ្យល់នៅលើក្រដាសរក្សាក្រដាសមិនអោយធ្លាក់ និងមិនអោយទឹកហូរចេញមកក្រៅ ។




**ម្យ៉ាងទៀតៈ**

សំភារៈ និងសារធាតុ :
- ដបកែវមួយ
- ស្បៃរុំរបួសមួយកំនាត់
- កៅស៊ូកង
- ទឹក

ដំណើរការពិសោធន៍ : ១- ដាក់កំនាត់ស្បៃនៅលើមាត់នៃដបហើយយកកៅស៊ូកងមកចង

២- ចាក់ទឹកបំពេញក្នុងដប

៣- ផ្កាប់ដបចុះក្រោមអោយរហ័ស ។

អង្កេត : ទឹកមិនធ្លាក់ចុះមកលើកំរាលទាំងអស់ទេ ។

សំនួរគន្លឹះ : ហេតុអ្វីបានជាទឹកមិនហូរចេញពីដបអស់?

ការពន្យល់ : សំពាធខ្យល់នៅលើស្បៃទប់មិនអោយទឹកចេញមកក្រៅ ។




## ដង់ស៊ីតេ

**ពិសោធន៍ទី ១៣ :** **ដុំឥដ្ឋ និង ដុំឈើ** សៀវភៅសិស្សថ្មី ទំព័រ ១១០, ១១១

សៀវភៅសិស្សថ្មី ទំព័រ ១១០, ១១១

គោលបំណង : សិស្សអាចសំគាល់ពីដង់ស៊ីតេរបស់អង្គធាតុរឹង ។

សំភារៈ និងសារធាតុ :
- ទឹក
- ដុំឥដ្ឋ
- ដុំឈើមានទំហំប៉ុនដុំឥដ្ឋ
- ដបធំដែលកាត់មាត់ចេញហើយថ្លាចំនួនពីរ

ដំណើរការពិសោធន៍ : ១- ចាក់បំពេញទឹកចូលក្នុងដបរហូតដល់ជិតពេញ

២- ដាក់ដុំឥដ្ឋនៅក្នុងដបមួយនិងដាក់ ដុំឈើនៅក្នុងដបមួយទៀត ។

អង្កេត : ដុំឥដ្ឋធ្លាក់ចុះទៅបាតនៃដបមួយ ហើយដុំឈើអណ្តែតឡើង ។

សំនួរគន្លឹះ : ចូរប្រៀបធៀបពីដង់ស៊ីតេរបស់អង្គធាតុទាំងបី តើមួយណាមានដង់ស៊ីតេធំជាងគេ? មួយណាមានដង់ស៊ីតេតូចជាងគេ?

ការពន្យល់ : ដុំឥដ្ឋមានដង់ស៊ីតេធំជាងដុំឈើ ហើយដុំឥដ្ឋមានដង់ស៊ីធំជាងទឹក ។






**ពិសោធន៍ទី ១៤:** **ភេសជ្ជៈកំប៉ុងមានស្ករតិចនិង ភេសជ្ជៈកំប៉ុងធម្មតា**

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

គោលបំណង : សិស្សអាចសំគាល់ និងប្រៀបធៀបពីដង់ស៊ីតេរបស់សូលុយស្យុង។

សំភារៈ និងសារធាតុ :
- ភេសជ្ជៈដែលមានស្ករតិចមួយកំប៉ុងនិង ភេសជ្ជៈធម្មតាមួយកំប៉ុង
- ទឹក
- ដបធំហើយថ្លាចំនួនពីរ

ដំណើរការពិសោធន៍ :
១- ចាក់បំពេញទឹកចូលក្នុងដបធំទាំង២រហូតដល់ជិតពេញ
២- ដាក់ភេសជ្ជៈធម្មតាមួយកំប៉ុងទៅក្នុងដបមួយដែលមានទឹក និងភេសជ្ជៈមួយកំប៉ុងទៀតទៅក្នុងដបទឹកមួយទៀត។

អង្កេត : កំប៉ុងភេសជ្ជៈមានជាតិស្ករតិចអណ្តែតឡើងហើយកំប៉ុងភេសជ្ជៈធម្មតាលិចចុះ។

សំនួរគន្លឹះ : ចូរប្រៀបធៀបពីដង់ស៊ីតេរបស់អង្គធាតុរាវទាំងពីរ តើមួយណាមានដង់ស៊ីតេធំជាងគេ? មួយណាមានដង់ស៊ីតេតូចជាងគេ?

ការពន្យល់ : នៅក្នុងកំប៉ុងនៃភេសជ្ជៈធម្មតាមានបរិមាណស្ករប្រហែល 3 ស្លាបព្រាធំៗ ដូចនេះ វាមានដង់ស៊ីតេ ធំជាងភេសជ្ជៈមានជាតិស្ករតិច (ហើយវាមានដង់ស៊ីតេធំជាងទឹក)។




សៀវភៅសិស្សថ្មី ទំព័រ ១១១
សៀវភៅសិស្សថ្មី ទំព័រ ១១១

**ពិសោធន៍ទី ១៥:** **ដបដាក់ទឹក និង ដបដាក់ទឹកអំបិល**

គោលបំណង : សិស្សអាចសំគាល់ និងប្រៀបធៀបពីដង់ស៊ីតេរបស់អង្គធាតុរាវ។

សំភារៈ និងសារធាតុ :
- ដបធំហើយថ្លាចំនួនពីរ
- ដបតូចៗចំនួនពីរដែលមានគំរប

- ទឹក
- អំបិល
- ស្លាបព្រា

ដំណើរការពិសោធន៍ : ការងារក្រុម

១- បំពេញទឹករហូតជិតពេញដបធំថ្លាទាំងពីរ

២- ចាក់បំពេញទឹកក្នុងដបតូចមួយហើយបិទគំរប ។ បន្ទាប់មកដាក់ទៅក្នុងដបធំមួយដែលបានចាក់បំពេញទឹករួច ។

៣- ចាក់បំពេញទឹកទៅក្នុងដបតូចមួយទៀតហើយបន្ថែមអំបិលមួយស្លាបព្រាម្តងៗចូលទៅដបតូច ។ កូរដើម្បីរំលាយអំបិលហើយបិទគំរប ។បន្ទាប់មកដាក់ទៅក្នុងដបធំមួយទៀតដែលបានចាក់បំពេញទឹករួច ។ ការងាររបស់អ្នក រួចរាល់ប្រសិនបើវាលិច ។ ប្រសិនបើវាមិនលិច ( ទៅបាតនៃដប) ត្រូវបន្ថែមអំបិលចូលដោយដាក់ម្តងមួយស្លាបព្រាពេញៗចូលទៅ រហូតដល់វាលិច ។

អង្កេត : ដបតូចដែលមានទឹកអណ្តែតឡើងហើយដបតូចដែលមានទឹកអំបិលលិចចុះ ។

សំនួរគន្លឹះ : ចូរប្រៀបធៀបពីដង់ស៊ីតេរបស់អង្គធាតុរាវទាំងពីរ តើមួយណាមានដង់ស៊ីតេធំជាងគេ? មួយណាមានដង់ស៊ីតេតូចជាងគេ?

ការពន្យល់ : ដបតូចដែលមានអំបិលលិចចុះពីព្រោះអំបិលនៅក្នុងទឹកបង្កើតបានជាសូលុយស្យុងដែលមានដង់ស៊ីតេធំជាងទឹក ។




**ពិសោធន៍ទី ១៦: ដុំទឹកកកលិច** សៀវភៅសិស្សថ្មី ទំព័រ ១១១
សៀវភៅសិស្សថ្មី ទំព័រ ១១១

គោលបំណង : សិស្សអាចប្រៀបធៀបពីដង់ស៊ីតេរបស់ទឹក ទឹកកក និងអាល់កុល ។

សំភារៈ និងសារធាតុ : - អាល់កុល ៩៧ ភាគរយ

- ទឹក
- ទឹកកកដុំ
- ដបតូចពីរដែលកាត់មាត់ចេញ

ដំណើរការពិសោធន៍ : ១- ចាក់ទឹកទៅក្នុងដបដែលបានកាត់រហូតដល់ជិតពេញរួចចាក់អាល់កុលទៅក្នុងដបដែលបានកាត់រួចមួយទៀត រហូតដល់ជិតពេញ

២- ដាក់ទឹកកកមួយដុំទៅក្នុងដបដែលមានទឹក ហើយមួយដុំទៀតទៅក្នុងដបដែលមានអាល់កុល ។

អង្កេត : ដុំទឹកកកនៅក្នុងទឹកគឺអណ្តែត ហើយដុំទឹកកកនៅក្នុងអាល់កុលគឺលិច ។

សំនួរគន្លឹះ : ចូរប្រៀបធៀបពីដង់ស៊ីតេរបស់ ទឹក អាល់កុល និងទឹកកក ។ តើមួយណាមានដង់ស៊ីតេធំជាងគេ មួយណាមានដង់ស៊ីតេទាបជាងគេ?

ការពន្យល់ :ទឹកកកដុំអណ្តែតនៅក្នុងទឹកហើយលិចនៅក្នុងអាល់កុលពីព្រោះតែដង់ស៊ីតេរបស់ពួកវាខុសគ្នា ។ (ដង់ស៊ីតេរបស់ទឹកគឺ ១.00ក្រាមក្នុងមួយមីលីលីត្រ ដង់ស៊ីតេរបស់ទឹកកកគឺ 0.៩២ ក្រាមក្នុងមួយមីលីលីត្រ ហើយដង់ស៊ីតេរបស់ អាល់កុល (អេតាណុល)គឺ 0.៧៩ ក្រាមក្នុងមួយមីលីលីត្រ)




**ពិសោធន៍ទី ១៧: ស៊ុតនៅក្នុងទឹក ស៊ុតនៅក្នុងទឹកមានអំបិលល្មម និងស៊ុតនៅក្នុងទឹកមានអំបិលច្រើន**

គោលបំណង : សិស្សអាចពន្យល់លក្ខណៈរបស់ស៊ុតនៅក្នុងទឹក ។ និងនៅក្នុងទឹកអំបិលដោយផ្អែកលើបញ្ញត្តិនៃដង់ស៊ី ។

សៀវភៅសិស្សថ្មី ទំព័រ ១១១

សំភារៈ និងសារធាតុ : 
- ដបទឹកប្លាស្ទិចមួយដែលបានកាត់មាត់ចេញ
- ស៊ុតឆៅមួយ
- អំបិល
- ទឹក
- ស្លាបព្រា

ដំណើរការពិសោធន៍ : ១- ដាក់ស៊ុតទៅក្នុងដបដែលបានបំពេញដោយទឹក ។(អង្កេតៈ វាលិច)

២- បន្ថែមអំបិលទៅក្នុងទឹកមួយស្លាបព្រាម្តងៗហើយកូររហូតដល់ស៊ុត
អណ្តែតនៅផ្ទៃកកណ្តាលនៃសូលុយស្យុង។

៣- បន្តបន្ថែមអំបិលម្តងមួយស្លាព្រាៗនិងកូររហូតដល់ស៊ុតអណ្តែតលើសូលុយស្យុង។



ស៊ុតនៅក្នុងទឹក (នៅបាត) | ស៊ុតនៅក្នុងទឹកអំបិលតិច (នៅពាក់កណ្តាល) | ស៊ុតនៅក្នុងទឹកអំបិលច្រើន (អណ្តែតនៅខាងលើ)

សំនួរគន្លឹះ : តើមានអ្វីកើតឡើងចំពោះស៊ុតនៅក្នុងទឹក និងក្នុងទឹកអំបិល? ហេតុអ្វីបានជាវាកើតបែបនេះ?

អង្កេត : ស៊ុតលិចក្នុងទឹក និងអណ្តែតក្នុងទឹកអំបិល។

ការពន្យល់ : ស៊ុតលិចក្នុងទឹកមានន័យថាវាមានដង់ស៊ីតេធំជាងទឹក តែតូចជាងទឹកអំបិលដែលជាហេតុធ្វើឱ្យវាអណ្តែត។

**ពិសោធន៍ទី ១៨:** **រលាយទឹកក្នុងដប** សៀវភៅសិស្សថ្មី ទំព័រ ១១១

សៀវភៅសិស្សថ្មី ទំព័រ ១១១

គោលបំណង : សិស្សអាចសំគាល់ពីដង់ស៊ីតេរបស់ទឹក និងប្រេងដែលមានលក្ខណៈផ្សេងគ្នា និងមូលហេតុដែលធ្វើឱ្យល័ក្ខរលាយក្នុងទឹកដោយផ្អែកលើបញ្ញត្តិនៃទម្រង់មូលេគុល។

សំភារៈ និងសារធាតុ :
- ទឹក
- ប្រេង
- ល័ក្ខអាហារ
- ដបប្លាស្ទិចតូចមួយមានគំរប

ដំណើរការពិសោធន៍ :
១- ចាក់ទឹកចូលក្នុងដប បរិមាណប្រហែលជាតិចជាងពាក់កណ្តាលដបបន្តិច។

២- បន្ថែមបរិមាណដូចគ្នានៃប្រេងឆាចូល។ ហើយទុកចន្លោះអោយនៅទំនេរខ្លះនៃផ្នែកខាងលើមាត់ដបប្រហែល ៣-៤ សង់ទីម៉ែត។

៣- បន្ថែមពីរដំណក់នៃល័ក្ខអាហារទៅក្នុងដប

៤- មួលគំរបដប ហើយដាក់ដបបញ្ឈរមួយកន្លែង ដើម្បីអោយប្រេងនិងទឹក អាចញែកចេញពីគ្នាបានល្អ ។

៥- យោលដបទៅមុខទៅក្រោយយឺតៗ ហើយមើលរលក ។

អង្កេត : ល័ក្ខអាហារឆ្លងកាត់ប្រេងចូលទៅក្នុងទឹក ធ្វើអោយទឹកមានពណ៌ ។

សំនួរគន្លឹះ : ហេតុអ្វីបានជាប្រេងមិនរលាយក្នុងទឹក ហើយអណ្តែតលើទឹក? ហេតុអ្វីបានជាល័ក្ខ រលាយក្នុងទឹក?

ការពន្យល់ : ប្រេងនិងទឹកមិនរលាយចូលគ្នាពីព្រោះពួកវាមានទំរង់ខុសគ្នា ហើយប្រេងមានដង់ស៊ីតេតូចជាងទឹក ។ ល័ក្ខអាហារមានទំរង់ ដូចគ្នានឹងទឹក ដូចនេះវាអាចឆ្លងកាត់ប្រេង ហើយលាយបញ្ចូលជាមួយទឹកបាន ។



# ជំពូកទី ២

# ខ្យល់ និង ឧស្ម័ន

## តើយើងដឹងថាមានខ្យល់ដោយរបៀបណា?

**ពិសោធន៍ទី ១៩: ប៉េងប៉ោងនៅក្នុងដប**

សៀវភៅសិស្សថ្មី ទំព័រ ១៣៦

<u>គោលបំណង</u> : សិស្សអាចសំគាល់ពីសំពាធខ្យល់ដែលមានឥទ្ធិពលទៅលើមាឌ។

<u>សំភារៈ និងសារធាតុ :</u>
- ប៉េងប៉ោងតូច
- ដបប្លាស្ទិចដែលមានគំរបភ្ជាប់និង វ៉ាល់ខ្យល់
- ស្នប់

<u>ដំណើរការពិសោធន៍ :</u> ការងារក្រុម

១- ដាក់ប៉េងប៉ោងនៅក្នុងដប ហើយ ផ្លុំវាអោយធំ (ដូចរូប)

២- ភ្ជាប់ដបជាមួយស្នប់ហើយសប់របូតដល់ដបក្លាយជារឹង

<u>អង្កេត</u> : ប៉េងប៉ោងតូចជាងមុនហើយដបរឹងជាងមុន ។

<u>សំនួរគន្លឹះ</u> : ហេតុអ្វីបានជាអ្នកពិបាកផ្លុំប៉េងប៉ោងក្នុងដប? ហេតុអ្វីបានជាប៉េងប៉ោងរួមតូចនៅពេលអ្នកសប់ខ្យល់បញ្ចូលក្នុងដប?

<u>ការពន្យល់</u> : នៅក្នុងដបមានសំពាធខ្យល់ទប់ធ្វើឱ្យយើងពិបាកក្នុងការផ្លុំប៉េងបោង ហើយនៅពេលយើងសប់ខ្យល់ទៅក្នុងដបគឺ បង្កើនសំពាធខ្យល់ធ្វើឱ្យប៉េងប៉ោងតូចជាងមុន។ (ដបនឹងប្រែជារឹងនៅពេលយើងសប់ខ្យល់ចូល ។






**ពិសោធន៍ទី ២០: ដបប្លាស្ទិច និង ទឹកក្តៅ**

គោលបំណង : សិស្សអាចសំគាល់ពីលក្ខណៈរបស់ខ្យល់នៅក្នុងដបនៅពេលដូរសីតុណ្ហភាព។

សំភារៈ និងសារធាតុ : - ដបប្លាស្ទិចមួយដែលមានគំរប
- ទឹកក្តៅ

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

ដំណើរការពិសោធន៍ ១: ១- ចាក់បំពេញទឹកក្តៅចូលក្នុងដបប្លាស្ទិចប្រមាណជា ១ ភាគ ៣នៃដប
២- បិទគំរប ហើយក្រឡុកប្រហែល ១០ដង
៣- ចាក់ទឹកចេញវិញ ហើយបិទគំរបវាភ្លាមៗ
៤- ទុកដបចោលរយៈពេលប្រហែល ២-៣ នាទីបន្ទាប់មកក្រលេកមើលដប

អង្កេត : ដបត្រូវបានកំពិត។

សំនួរគន្លឹះ : ហេតុអ្វីបានជាដបកំពិត?

ការពន្យល់ : នៅពេលដែលអ្នកចាក់ទឹកក្តៅចូលទៅក្នុងដប ហើយបិទគំរបដបគឺជា ពេលដែលខ្យល់ចុះត្រជាក់ នាំអោយមាឌវាត្រូវបានថយចុះដូចនេះសំពាធខាងក្រៅខ្លាំងរួមសង្កត់ធ្វើអោយដបកំពិត។



ដំណើរការពិសោធទី២: មួលគំរបដបចេញវិញ។

អង្កេត : ដបនឹងត្រលប់មករកភាពដើមវិញ។

ការពន្យល់ : ខ្យល់នៅខាងក្រៅដបមកបំពេញដបវិញ ដោយសារសំពាធខ្យល់ខាងក្រៅធំជាងសំពាធខ្យល់នៅក្នុងដប ( ចូរចងចាំថា មានខ្យល់មួយចំនួនចេញពីដបនៅពេលចាក់ទឹកក្ដៅចូល) ។

## អត្តសញ្ញាណកម្ម អុកស៊ីសែន និង ឧស្ម័នកាបូនិច

**ពិសោធន៍ទី ២១: ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន** សៀវភៅសិស្សថ្មី ទំព័រ ១៣៨

គោលបំណង : សិស្សអាចចេះពីទង្វើ និងអត្តសញ្ញាណឧស្ម័នអុកស៊ីសែន។

សំភារៈ និងសារធាតុ :
- អ៊ីដ្រូសែនពែអុកស៊ីត ($H_2O_2$)
- ថ្លើមសត្វ
- បំពង់សាក
- ឈើ ឬ ឫស្សី
- ឈើគូស

ដំណើរការពិសោធន៍ :

១- ដាក់បំណែកថ្លើមសត្វតូចៗ( ទំហំប្រហែល២គ្រាប់អង្ករ) ទៅក្នុងបំពង់សាកមួយ

២- ដុតចុងឈើហើយផ្លុំភ្លើងពន្លត់ដោយទុកតែរងើក

៣- បន្ថែម $H_2O_2$ ប្រមាណជា ពីរភាគបីនៃបំពង់សាកទៅក្នុងបំពង់សាកដែលមានថ្លើម

៤- ដាក់ឈើដែលមានរងើកនៅខាងចុងចូលទៅក្នុងបំពង់សាកនៅពេលដែលមានពពុះឧស្ម័នភាយឡើង

អង្កេត : ពេលដែលមានពពុះភាយឡើងក្នុងបំពង់សាក ឈើដែលមានរងើកនឹងឆេះជាអណ្ដាត ភ្លើងឡើងវិញ។

សំនួរគន្លឹះ : តើមានអ្វីកើតឡើងនៅក្នុងបំពង់សាកពេលបន្ថែមទឹកអុកសីសែនចូល? តើឧស្ម័ននោះជាអ្វី?

ការបន្យល់ : មានពពុះគឺមានន័យថាមានឧស្ម័នភាយឡើង ហើយឈើមានតែរងើកឆេះជាអណ្ដាតភ្លើងឡើងវិញ គឺមានន័យថាឧស្ម័នដែលភាយឡើងនោះជាឧស្ម័ន អុកស៊ីសែន។






**ពិសោធន៍ទី ២២: ទង្វើសូលុយស្យុងទឹកកំបោរថ្លា**

មិនមានឯកសារយោងនៅក្នុងសៀវភៅ អត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

គោលបំណង : សិស្សអាចចេះធ្វើសូលុយស្យុងទឹកកំបោរថ្លា។

សំភារៈ និងសារធាតុ : - កែវ ២
- ជីឡាវដែលមានសំឡីច្រោះ
- ឈើសំរាប់កូរ
- កំបោរ CaO
- ទំរជើងបី

ដំណើរការពិសោធន៍ : ១- ដាក់ដុំកំបោរ CaO ប្រមាណប៉ុនមេដៃទៅក្នុងកែវមួយ
២- បន្ថែមទឹករហូតជិតដល់ពេញ
៣- ច្រោះល្បាយ

សំនួរគន្លឹះ : តើអ្នកទទួលអ្វីបន្ទាប់ពីច្រោះ?

អង្កេត និង ការពន្យល់ : សូលុយស្យុងថ្លាដែលបានពីផលច្រោះជា សូលុយស្យុងទឹកកំបោរថ្លា( បានពីប្រតិកម្មរវាងកំបោរ នឹងទឹក)




**ពិសោធន៍ទី ២៣: ទង្វើ និង អត្តសញ្ញាណកម្មឧស្ម័នកាបូនិច**

សៀវភៅសិស្សថ្មី ទំព័រ ១៣៨

គោលបំណង : សិស្សអាចចេះពីទង្វើ និងអត្តសញ្ញាណឧស្ម័នកាបូនិចដែលបានពីប្រតិកម្ម។

សំភារៈ និងសារធាតុ : - មេនំ
- កំប៉ុងថ្លាតូចមួយដែលបានកាត់រួច

- ទឹកខ្មេះ
- ទឹកកំបោរថ្លា

ដំណើរការពិសោធន៍ : ១- ដាក់ម្សៅមេនំមួយស្លាបព្រាទៅក្នុង កំប៉ុងថ្លាតូចមួយដែលបានកាត់រួច

២- ថែមទឹកខ្មេះប្រហែលជា ១ រឺ ២ សង់ទីម៉ែត្រទៅក្នុងកំប៉ុងខាងលើ

៣- ចាក់ទឹកកំបោរថ្លាបន្តិចទៅក្នុងកំប៉ុងមួយទៀតហើយដាក់វាបញ្ឈរឡើង

៤- ផ្ទេរឧស្ម័នកាបូនិចដែលមើលមិនឃើញពីកំប៉ុងដែលមានមេនំនិងទឹកខ្មេះទៅក្នុង កំប៉ុងដែលមានទឹកកំបោរ ។ ក្រលេងវាម្តងទៀត ។

អង្កេត : ទឹកកំបោរថ្លាប្រែជាល្អក់ ។

សំនួរគន្លឹះ : តើឧស្ម័នអ្វីដែលបានពីប្រតិកម្មរវាងទឹកខ្មេះ និងម្សៅមេនំ (ម្សៅសូដា)? តើមានអ្វីកើតឡើងចំពោះទឹកកំបោរថ្លា?

ការពន្យល់ : ប្រតិកម្មរវាងទឹកខ្មេះ និងម្សៅសូដា កកើតបានឧស្ម័នកាបូនិច ហើយទឹកកំបោរថ្លាក្លាយជាល្អក់មានន័យថាឧស្ម័នដែល កកើតឡើងទៅប្រតិកម្មជាមួយទឹកកំបោរដែលជាហេតុធ្វើឱ្យទឹកកំបោរប្រែជាល្អក់ ។ ទឹកកំបោរថ្លាត្រូវប្រើប្រាស់ដើម្បីអត្តសញ្ញាណឧស្ម័នកាបូនិច ។




**ពិសោធន៍ទី ២៤: ការផ្ទុំឧស្ម័នកាបូនិច** សៀវភៅសិស្សថ្មី ទំព័រ ១៣៨
សៀវភៅសិស្សថ្មី ទំព័រ ១៣៨

គោលបំណង : អត្តសញ្ញាណឧស្ម័នដង្ហើម $CO_2$ ដោយប្រើទឹកកំបោរថ្លា ។

សំភារៈ និងសារធាតុ :
- ទុយោ
- កំប៉ុងថ្លាតូចមួយដែលបានកាត់មាត់រួច
- ទឹកកំបោរថ្លា

ដំណើរការពិសោធន៍ : ១- ចាក់ទឹកកំបោរទៅក្នុងកំប៉ុងថ្លាតូចមួយដែលបានកាត់មាត់រួច ។

២- យកបំពង់បឺតផ្លុំខ្យល់ចូលក្នុងទឹកកំបោរ

អង្កេត : ទឹកកំបោរថ្លាក្លាយជាល្អក់ ។

សំនួរគន្លឹះ : ហេតុអ្វីទឹកកំបោរថ្លាប្រែជាល្អក់?

<u>ការពន្យល់</u> : ទឹកកំបោរថ្លាត្រូវបានប្រើយកមកធ្វើតេស្តរកឧស្ម័នកាបូនិច ។ ដូចនេះ នៅពេលទឹកកំបោរថ្លាក្លាយជាល្អក់នៅពេលដែលអ្នកផ្លុំតាមបំពង់បឺតគឺអ្នកកំពុងតែផ្លុំឧស្ម័នកាបូនិចពីក្នុងមាត់របស់អ្នកទៅក្នុងទឹកកំបោរថ្លានោះ ។



# ផ្នែកទី ២ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៨

## Improved Basic Education in Cambodia Project (IBEC)

WORLD EDUCATION, INC

## មាតិកា


**ពិសោធន៍ទី ១** : ការបង្ហាញពីតារាងខួប

**ពិសោធន៍ទី ២** : ការវះថ្មពិល យកដែក (Fe) ស័ង្កសី (Zn) កាបូន (C) និងម៉ង់កាណែសឌីអុកស៊ីត ($MnO_2$)

**ពិសោធន៍ទី ៣** : ធ្វើតេស្តដែកជាមួយមេដែក

**ពិសោធន៍ទី ៤** : ប្រតិកម្មរវាងស័ង្កសីជាមួយ HCl

**ពិសោធន៍ទី ៥ :** ទង្វើ និង ការធ្វើតេស្តឧស្ម័នអុកស៊ីសែន

**ពិសោធន៍ទី ៦ :** ទង្វើឧស្ម័នអុកស៊ីសែន

**ពិសោធន៍ទី ៧** : ចំហេះកាបូន

**ពិសោធន៍ទី ៨** : ចំហេះអ៊ីដ្រូសែន

**ពិសោធន៍ទី ៩ :** ច្បាប់រក្សាម៉ាស

**ពិសោធន៍ទី ១០ :** លាយកំទិចដែក ជាមួយដីខ្សាច់ - ធ្វើតេស្តជាមួយនឹងមេដែក

**ពិសោធន៍ទី ១១** : លាយអំបិលជាមួយទឹក

**ពិសោធន៍ទី ១២** : ការញែកល្បាយ

**ពិសោធន៍ទី ១៣** : ការធ្វើគ្រីស្តាល់ស្ករស

**ពិសោធន៍ទី ១៤** : ក្រូម៉ាតូក្រាហ្វីដីស (ពណ៌វិធីដីស)

# ជំពូកទី ១

# រូបធាតុ ទ្រឹស្តីនៃម៉ូលេគុល និង អាតូម

**ពិសោធន៍ទី ១: សំរាប់គ្រូ: បង្ហាញអំពីតារាងខួបគីមី** សៀវភៅសិស្សទំព័រ ១០៦

សៀវភៅសិស្សទំព័រ ១០៦

គោលបំណង : សិស្សអាចឆ្លើយសំនួរទាក់ទងនឹងតារាងខួបនៃធាតុគីមី និងអាចអាននិងស្គាល់ឈ្មោះធាតុគីមី ។

សំភារៈ និងសារធាតុ:
- តារាងខួបនៃធាតុគីមី
- ក្រដាសអាលុយមីញ៉ូម
- ខ្សែទង់ដែងដែលយកចេញពីខ្សែភ្លើង
- បន្ទះទង់ដែង
- ដែក (ដែលបានពីថ្មពិល)
- បន្ទះសង្ក័សី (ដែលបានពីថ្មពិល)
- បណ្តូលកាបូន (ដែលបានពីថ្មពិល)
- ភាគសំណាកៈ អំបិល ទឹក ទង់ដែងស៊ុលផាត និង ស្ករស (ស៊ុចក្រូស)

ដំណើរការពិសោធន៍:

១- បង្ហាញសិស្សអំពីតារាងខួបនៃធាតុគីមី ។

២- បង្ហាញពីខ្សែបន្ទាត់ដែលបែងចែករវាង លោហៈ និងអលោហៈ ។

៣- បង្ហាញពីក្រុម (ជាមួយឈ្មោះ) និងខួប ។

៤- បង្ហាញសិស្សពីធាតុដែលជាអង្គធាតុរឹង រាវ ឧស្ម័ន ធាតុវិទ្យុសកម្ម និង ធាតុសំយោគដោយផ្អែកទៅលើពណ៌របស់ធាតុដែលមាននៅក្នុងតារាងខួប ។

៥- បង្ហាញអំពីភាគសំណាកនៃសន្លឹកអាលុយមីញ៉ូម បន្ទះអាលុយមីញ៉ូមដែលបានមក

ពីកំប៉ុងភេសជ្ជៈ ឬកំប៉ុងភេសជ្ជៈដែលបង្ហាញស្រទាប់អាលុយមីញ៉ូម ទង់ដែងដែល ប៉ូនដែល




**ការពន្យល់បន្ថែម:** ពេលពន្យល់ពីតារាងខួបសូមភ្ជាប់ជាមួយការពន្យល់ខាងក្រោម។

**និមិត្តសញ្ញាតំណាងឱ្យធាតុគីមី : និមិត្តសញ្ញាជាអក្សរ:** អាតូម O H Al Cu Fe Zn

**ពិសោធន៍ទី១ :** ហែកសន្លឹកអាលុយមីញ៉ូមទៅជាបំណែកតូចៗ ហើយហែកក្រដាសដែលមានរូបភាព អាលុយមីញ៉ូម (Al) ជាបំណែកតូចៗ។

សៀវភៅសិស្សទំព័រ ១១៦
សៀវភៅសិស្សទំព័រ ១១៦

**ទាំងនេះទាក់ទង ទៅនឹង** រូបភាពនៃអង្គធាតុរឹង រាវ និង ឧស្ម័ននៅក្នុងថ្នាក់ទី៧។

**ម៉ូលេគុលឌីអាតូមៈ** ម៉ូលេគុល $O_2$ $H_2$ (អាតូមពីរ រឺ ច្រើនចងសម្ព័ន្ធជាមួយគ្នា)

**រូបភាពៈ** ឧស្ម័នអុកស៊ីសែន $O_2$ **រូបភាពៈ** ឧស្ម័នអ៊ីដ្រូសែន $H_2$






**ភាគសំណាកគំរូនៃសមាសធាតុមួយចំនួនៈ** អំបិលសំឡ (NaCl), ទឹក ($H_2O$), សាច់ជូរខៀវ ($CuSO_4$), ស្ករស ($C_{12}H_{22}O_{11}$), ឧស្ម័នកាបូនិច ($CO_2$) (ធាតុពីរ រឺច្រើន,.,.)។

សមាសធាតុទាំងអស់នេះប្រើនិម្មិតសញ្ញានៃធាតុគីមីជាច្រើន និងបង្ហាញពីរូបមន្តគីមីនៃសារធាតុ។

**ការបង្ហាញពីម៉ូលេគុល :** ទឹក $H_2O$ និង ឧស្ម័នកាបូនិច $CO_2$






**ពិសោធន៍ទី ២ៈ ការវះថ្មពិល : ដកយកដែក (Fe) សង្ក័សី (Zn) ម៉ង់កាណែសឌីអុកស៊ីត ($MnO_2$) និង កាបូន (C)**

សៀវភៅសិស្សទំព័រ ១០៨

សៀវភៅសិស្សទំព័រ ១០៨

គោលបំណង : សិស្សអាចសំគាល់ពីធាតុគិមីដែលមាននៅក្នុងថ្មពិល។

សំភារៈ និងសារធាតុ:
- ថ្មពិល
- កន្ត្រៃ

ដំណើរការពិសោធន៍:

១- បែកថ្មពិលឱ្យរបើកឡើង។

២- ដកយកបន្ទះលោហៈខាងក្រៅ (នេះគឺជា ដែក (Fe))។

៣-កាត់ និងហែកស្រទាប់ប្លាស្ទិចចេញ។

៤- ដកបន្ទះលោហៈដែលនៅបន្ទាប់ពី បន្ទះដែក និងប្លាស្ទិច (វាជាសង្ក័សី (Zn))

៥- ដកគំរបចេញ ហើយដកយកបណ្តូលពណ៌ខ្មៅចេញមក នេះជាស្នូលថ្មពិល (វាជាកាបូន (C) )

៦- ដកយកម្សៅពណ៌ខ្មៅជុំវិញបណ្តូលកាបូន (វាជាម៉ង់កាណែសឌីអុកស៊ីត($MnO_2$))

<u>សំនួរគន្លឹះ</u> : តើអ្នកអាចឱ្យឈ្មោះនៃធាតុ និងសារធាតុគីមីនៅក្នុងថ្មពិលបានឬទេ? អ្វីខ្លះ?

<u>ការពន្យល់</u> : សូមមើលរូបភាពនៅក្រោម:



ថ្មពិល



សំបកដែកខាងក្រៅ



ស្រទាប់ប្លាស្ទិច
នៅចន្លោះស្រទាប់ ដែក




សំបកស័ង្កសីខាងក្នុង



បណ្តូលកាបូនខាងក្នុងថ្មពិល

## <u>ពិសោធន៍ទី ៣:</u> <u>ការធ្វើតេស្តលោហ:ដែកជាមួយមេដែក</u>

<u>គោលបំណង</u> : សិស្សអាចសំគាល់ពីលក្ខណ:របស់ដែកពេលដាក់ជិតមេដែក (មេដែកឆក់ដែកជាប់)។

<u>សំភារ: និងសារធាតុ:</u> - ស្រទាប់ខាងក្រៅនៃថ្មពិល(ដែក)

- មេដែក

<u>ដំណើរការពិសោធន៍:</u> ដាក់មេដែកនៅលើស្រទាប់លោហ: (ដែក)។

សង្កេត: ដែកជាប់នឹងមេដែក។

សំនួរគន្លឹះ : តើអ្នកអាចសរុបពីលក្ខណៈរបស់ដែកពេលដាក់ជិតមេដែកបានយ៉ាងដូចម្តេច?

ការពន្យល់ :ដែក គឺជាប្រភេទធាតុគីមីមួយក្នុងចំណោមប្រភេទធាតុគីមីពីរ បីប្រភេទដែលឆក់ជាបនឹងមេដែក។

**ប្រតិកម្មគីមី**

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

**ពិសោធន៍ទី ៤: ប្រតិកម្មរវាងសង្កសី ជាមួយនិងអាស៊ីតក្លរីឌ្រិច**

គោលបំណង : សិស្សអាចសំគាល់ពីផលិតផលដែលកើតចេញពីប្រតិកម្មរវាងស័ង្កសីជាមួយអាស៊ីតក្លរីឌ្រិច ។

សំភារ: និងសារធាតុ:
- សង្កសី( យកពីថ្មពិល)
- អាស៊ីតក្លរីឌ្រិច ( ទឹកលាងបង្គន់) ប្រើតែទឹកលាងបង្គន់ម៉ាក Super OK ដែលមាន Hydrochoric acid 13%, Phosphoric acid 27% និង Nonylphenol Polyethylence glycol ether 1.0%
- បំពង់សាក ជើងទម្របំពង់សាក និង ដង្កៀបចាប់បំពង់សាក

ដំណើរការពិសោធន៍:
១- ដាក់កំទេចសង្ក័សីពីរបីដំរៀក ទៅក្នុងបំពង់សាក។
២- បន្ថែម អាស៊ីតក្លរីឌ្រិចប្រហែល ២ ទៅ ៣ សង់ទីម៉ែត្រទៅក្នុងបំពង់សាក។



<u>សង្កេត</u> :ពពុះកើតឡើងនៅពេល អាស៊ីតក្លរីឌ្រិចត្រូវបានបន្ថែមទៅលើ សង្កសី ។

<u>សំនួរគន្លឹះ</u> : តើមានអ្វីកើតចេញពីប្រតិកម្ម?

<u>ការពន្យល់</u> : ឧស្ម័ន កើតឡើងបង្ហាញពីប្រតិកម្មរវាងស័ង្កសី និងអាស៊ីតក្លរីឌ្រិច ។

<u>សមីការសំរាប់ប្រតិកម្ម:</u> $Zn + 2HCl \longrightarrow ZnCl_2 + H_2\uparrow$

## <u>ពិសោធន៍ទី ៥: បន្ថែមអ៊ីដ្រូសែនពែរអុកស៊ីត ($H_2O_2$) ទៅក្នុងម្សៅពណិខ្មៅ ($MnO_2$) និង សំរាប់ តេស្តអុកស៊ីសែន</u>

<u>គោលបំណង</u> : សិស្សអាចធ្វើ និងអត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែនក្នុងនាមជាឧស្ម័នទ្រទ្រង់ចំហេះ ។

<u>សមីការតាងប្រតិកម្ម:</u> $2H_2O_2 \xrightarrow{MnO_2} 2H_2O + O_2\uparrow$

<u>សំភារ: និងសារធាតុ:</u>
- ម្សៅពណិខ្មៅម៉ង់កាណេសឌីអុកស៊ីត ($MnO_2$) ដែលបានមកពីថ្មពិល
- អ៊ីដ្រូសែនពែរអុកស៊ីត ឬទឹកអុកស៊ីសែនេ ($H_2O_2$)
- បំពង់សាក
- ចង្កឹះឈើ ឬចង្កឹះឬស្សី
- ឈើគូស

មិនមានឯកសាយោងនៅក្នុងសៀវភៅ អត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យ សិស្សយល់ ។

<u>ដំណើរការពិសោធន៍:</u>

១- ដាក់ម្សៅពណិខ្មៅបន្តិចចូលទៅក្នុងបំពង់សាក ។

២- បន្ថែមអ៊ីដ្រូសែនពែរអុកស៊ីត ($H_2O_2$) ប្រហែលមួយភាគបីនៃបំពង់សាក ទៅក្នុងបំពង់សាកដែលមានម្សៅពណិខ្មៅ ។

៣- ដុតចង្កឹះឈើ ហើយផ្លុំពន្លត់ភ្លើងអោយរលត់សល់តែរងើក

៤- ដាក់ចង្កឹះឈើដែលមានរងើកទៅក្នុងបំពង់សាក



➡ រងើកភ្លើង

សង្កេត : ឈើឆាបឆេះក្លាយជាអណ្តាតភ្លើងឡើងវិញ។

សំនួរគន្លឹះ : តើមានឧស្ម័នអ្វីកើតចេញពីប្រតិកម្ម? តើមានអ្វីកើតឡើងចំពោះឧស្ម័ននេះពេលគេដាក់រងើកភ្លើងក្បែរ?

ការពន្យល់ : អុកស៊ីសែនទ្រទ្រង់ចំហេះ។

# ជំពូកទី ២

# ប្រតិកម្មគីមី

## ពិសោធន៍ទី ៦: ទង្វើអុកស៊ីសែន

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

គោលបំណង : សិស្សអាចធ្វើឧស្ម័នអុកស៊ីសែន ។

សំភារៈ និងសារធាតុ: - កែវអែកឡែនតូចមួយចំនុះ១00ម.ល
- ចំនិតនៃថ្លើមសត្វ
- អ៊ីដ្រូសែនពែរអុកស៊ីត ($H_2O_2$ )

ដំណើរការពិសោធន៍: ១- ដាក់ចំនិតថ្លើមសត្វ (ទំហំប៉ុនកូនដៃ) ចូលទៅក្នុងកែវអែកឡែន
២- ចាក់អ៊ីដ្រូសែនពែរអុកស៊ីត ($H_2O_2$ ) ចូលទៅក្នុងកែវឱ្យលិចលើថ្លើម (មើលរូប)

សង្កេតៈ មានពពុះកើតឡើង។

សំនួរគន្លឹះ : តើមានអ្វីកើតចេញពីប្រតិកម្ម? តើមានឧស្ម័នអ្វីកើតចេញពីប្រតិកម្ម?

ការពន្យល់: ពពុះនេះបង្ហាញថាមានឧស្ម័នកើតឡើង ហើយឧស្ម័ននោះជាឧស្ម័នអុកស៊ីសែន ។
រំលឹកការពិសោធទី ២១ ថ្នាក់ទី៧ -ទង្វើ និងការធ្វើតេស្តអុកស៊ីសែន។



O O O H$_2$O$_2$

**ពិសោធន៍ទី ៧ : ចំហេះកាបូន**

សៀវភៅសិស្សទំព័រ ១៣៩
សៀវភៅសិស្សទំព័រ ១៣៩

គោលបំណង : សិស្សអាចសំគាល់ពីចំហេះរបស់កាបូនដោយប្រើបញ្ញតិចំហេះ និងលក្ខណៈរបស់អុកស៊ីសែន ។

សំភារៈនិងសារធាតុ:
- ធ្យូងមួយដុំ
- ខ្សែលួស
- កែវអែកឡែនមួយដែលមានអុកស៊ីសែនបានមកពីពិសោធន៍ទី៦
- ចង្កៀងអាល់កុល
- ឈើគូស

ដំណើរការពិសោធន៍:
១- ចងធ្យូងមួយដុំជាមួយខ្សែលួស ។
២- ដុតធ្យូងដោយប្រើចង្កៀងអាល់កុល ។
៣- ដាក់រងើកធ្យូងទៅក្នុងកែវអុកស៊ីសែន ។




សង្កេត : រងើកធ្យូងឆេះក្លាយជាអណ្តាតភ្លើងឡើង ។

សំនួរគន្លឹះ : ហេតុអ្វីបានជាដុំធ្យូងឆេះ?

ការពន្យល់ : អុកស៊ីសែនទ្រទ្រង់ចំហេះ ។

**ពិសោធន៍ទី ៨ : ចំហេះអ៊ីដ្រូសែន (Al + HCl)**

សៀវភៅសិស្សទំព័រ ១៤០
សៀវភៅសិស្សទំព័រ ១៤០

គោលបំណង : សិស្សអាចកំណត់ពីចំហេះ និងលក្ខណៈរបស់អ៊ីដ្រូសែន ។

សំភារៈ និងសារធាតុ:
- បំពង់សាកពិរ
- Al （ក្រដាសអាលុយមីញ៉ូម）

- HCl (ទឹកលាងបង្គន់)
- ឈើគូស
- ចង្កឹះឈើ

ដំណើរការពិសោធន៍: ១- ដាក់ក្រដាសអាលុយមីញ៉ូមមួយជំរៀកតូចទៅក្នុងបំពង់សាក។
២- បន្ថែមអាស៊ីតក្លរីឌ្រិចទៅក្នុងបំពង់សាកប្រហែលមួយភាគបីនៃបំពង់សាកទៅក្នុងបំពង់សាកដែលមាន Al ។
៣- ដុតចង្កឹះឈើ ហើយដាក់វាទៅលើមាត់បំពង់សាក។




សំនួរគន្លឹះ : តើមានអ្វីកើតឡើងពីប្រតិកម្ម? តើឧស្ម័ននោះជាឧស្ម័នអ្វី? តើមានអ្វីកើតឡើងពេលឧស្ម័ននេះឆេះ? តើវាខុសពីឧស្ម័នអុកស៊ីសែនយ៉ាងដូចម្តេច?

សង្កេត : ពពុះកើតឡើងនៅពេលដែលអាស៊ីតក្លរីឌ្រិចត្រូវបានចាក់បន្ថែមលើ ។ល ។ ឈើដែលឆេះបានបង្កើតជាសំលេងផ្ទុះនៅពេលដាក់ចំកន្លែងមានឧស្ម័នអ៊ីដ្រូសែន។

ការពន្យល់ : ឧស្ម័នអ៊ីដ្រូសែនឆេះក្នុងខ្យល់ (អុកស៊ីសែន) បង្កើតជាសំលេងផ្ទុះ។

សមីការតាងប្រតិកម្ម:

$$2Al + 6HCl \rightarrow 2AlCl_3 + 3H_2$$

$$2H_2 + O_2 \rightarrow 2H_2O$$

(ចំហេះឧស្ម័នអ៊ីដ្រូសែន បង្កើតជាសំលេងផ្ទុះ)

## ពិសោធន៍ទី ៩ : ច្បាប់រក្សាម៉ាស

សៀវភៅឯកសារបំប៉ន ទំព័រ ៦៨
សៀវភៅឯកសារបំប៉ន ទំព័រ ៦៨
សៀវភៅសិស្សទំព័រ ១៤១
សៀវភៅសិស្សទំព័រ ១៤១

គោលបំណង : សិស្សអាចពន្យល់ពីច្បាប់រក្សាម៉ាសតាមការអង្កេតក្នុងពិសោធន៍។

សំភារៈ និងសារធាតុ: - ក្រឡកែវមួយដែលមានគំរប

- បំពង់សាកមួយ
- ជញ្ជីងមួយ
- សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត 5M
- សូលុយស្យុងទង់ដែងស៊ុលផាត 1M
- ថង់ប្លាស្ទិចមួយដែលមានដៃកាន់

ដំណើរការពិសោធន៍: ១- ចាក់ សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត 5M ប្រមាណជាមួយ ឬ ពីរ សង់ទីម៉ែតនៃក្រឡទៅក្នុង ក្រឡកែវតូចមួយ ហើយដាក់សូលុយស្យុងទង់ដែងស៊ុលផាត 1M ទៅក្នុងបំពង់សាកតូចមួយ ។

២- ដាក់បំពង់សាកចូលទៅក្នុងក្រឡ បន្ទាប់មកបិទគំរបហើយថ្លឹងវា

៣- ថ្លឹងក្រឡដោយដាក់វាទៅក្នុងថង់ប្លាស្ទិច ហើយយកជញ្ជីងយួរដៃថ្លឹងវា

៤- លាយសូលុយស្យុងបញ្ចូលគ្នាដោយផ្អៀងក្រឡដែលបានបិទគំរបជិត ។ ថ្លឹងក្រឡម្តងទៀត ។




សង្កេត : បន្ទាប់ពីការលាយបញ្ចូលគ្នា មានកករកើតឡើងក្នុងសូលុយស្យុង ប៉ុន្តែម៉ាសរបស់ក្រឡដែលមានសូដ្យូមអ៊ីដ្រុកស៊ីត និងមានទង់ដែងស៊ុលផាតមុនពេលលាយស្មើនឹងម៉ាសក្រោយលាយហើយ ។

សំនួរគន្លឹះ : តើម៉ាសសរុបរបស់អង្គធាតុប្រតិករ (ស៊ូត និងទង់ដែងស៊ុលផាត) ស្មើនឹងម៉ាសអង្គធាតុកកើត (ទង់ដែងអ៊ីដ្រុកស៊ីត និងសូដ្យូមស៊ុលផាត) ឬទេ?

ការពន្យល : ច្បាប់រក្សាម៉ាសពោលថា ម៉ាសសរុបនៃអង្គធាតុប្រតិករស្មើនឹងម៉ាសនៃអង្គធាតុកកើត ។ នៅក្នុងប្រតិកម្មគីមី ។ រូបធាតុមិនត្រូវបានបង្កើត ឬបាត់បង់ ទេ ។

សមីការតាងប្រតិកម្ម: $2NaOH (aq) + CuSO_4 (aq) \rightarrow Cu(OH)_2 (s) + Na_2SO_4 (aq)$

# ជំពូកទី ៣

## ល្បាយ

**ពិសោធន៍ទី ១០ : លាយល្បាយដែកជាមួយខ្សាច់ តេស្តជាមួយមេដែក (អេតេរ៉ូសែន)**

គោលបំណង : សិស្សអាចអត្តសញ្ញាណពីល្បាយនៃអង្គធាតុរឹងមិនស្មើសាច់ និងការញែកល្បាយ ។

សំភារៈ និងសារធាតុ:
- ដែក
- ខ្សាច់
- មេដែក
- ដបតូចមួយដែលបានកាត់មាត់រួចហើយ

សៀវភៅសិស្សទំព័រ ១៥៤
សៀវភៅសិស្សទំព័រ ១៥៤

ដំណើរការពិសោធន៍: ១- លាយដែកជាមួយខ្សាច់នៅក្នុងដបដែលបានកាត់មាត់រួចហើយ ។

២- ប្រើមេដែកដើម្បីញែកយកដែកចេញពីខ្សាច់ ។

សង្កេតៈ ដែកឆក់ជាប់ជាមួយមេដែក ហើយខ្សាច់នៅក្នុងដបដដែល ។

សំនួរគន្លឹះ : តើអ្នកអាចញែកល្បាយនេះបានដែរឬទេ? ដោយរបៀបណា?

ការពន្យល់: ល្បាយអាចត្រូវបានញែកដោយលក្ខណៈរូប ។

**ពិសោធន៍ទី ១១ : លាយអំបិលជាមួយទឹក (អូម៉ូសែន)**

សៀវភៅសិស្សទំព័រ ១៥៣
សៀវភៅសិស្សទំព័រ ១៥៣

<u>គោលបំណង</u> : សិស្សអាចអត្តសញ្ញាណពីល្បាយនៃអង្គធាតុរឹងនិងរាវស្មើសាច់ ។

<u>សំភារៈ និងសារធាតុ:</u>

- អំបិល
- ទឹក
- ដបកាត់តូចមួយ
- ស្លាបព្រា

<u>ដំណើរការពិសោធន៍:</u>

១- ដាក់អំបិលមួយស្លាបព្រានៅក្នុងដបតូចមួយ ។

២- ថែមទឹកដើម្បីរំលាយអំបិល ។

<u>សង្កេត</u> : អំបិលរលាយក្នុងទឹក ។

<u>សំនួរគន្លឹះ</u> : តើអ្នកអាចសិស្សអាចសំគាល់ថាអំបិលនៅផ្នែកណាមួយក្នុងទឹកបានទេ? តើវាជាល្បាយមិនស្មើសាច់ឬទេ? បើមិនមែនតើវាជាល្បាយអ្វី?

<u>ការពន្យល</u> : អំបិលត្រូវបានរលាយក្នុងទឹក ហើយបង្កើតបានជាសូលុយស្យុងអំបិល ដែលមើលទៅដូចជាទឹក នេះជាសូលុយស្យុងល្បាយស្មើសាច់ ( អូម៉ូសែន) ។

## <u>ពិសោធន៍ទី ១២:</u> <u>ការញែកល្បាយ</u>

សៀវភៅសិស្សទំព័រ ១៥៩, ១៦០
សៀវភៅសិស្សទំព័រ ១៥៩, ១៦០

<u>គោលបំណង</u> : សិស្សអាចចេះពីរបៀបញែកល្បាយស្មើសាច់ និងមិនស្មើសាច់ ។

<u>សំភារៈ និងសារធាតុ:</u>

- ខ្សាច់
- អំបិល
- ទឹក
- ដបកាត់មាត់តូចមួយ
- ជីឡាវ
- សំឡី
- កែវបេស៊ែរ ១០០ម.ល ( អាចដាំទឹកបាន)
- ទម្រជើងបី
- ស្លាបព្រា
- ចង្កៀងអាល់កុល
- ដង្កៀបធំមួយ ( សំរាប់ចាប់កែវបេស៊ែរក្តៅ)
- ឈើគូស
- បន្ទះសំណាញ់ដែក

<u>ដំណើរការពិសោធន៍:</u>

១- លាយខ្សាច់មួយស្លាបព្រា និង អំបិលមួយស្លាបព្រាទៅក្នុងដបកាត់មាត់មួយ ។

២- ចាក់ទឹកចូលក្នុងដបខាងលើដែលមានល្បាយ ហើយកូរវារហូតដល់ អំបិលរលាយក្នុងទឹកអស់ ។

៣- ច្រោះល្បាយដោយប្រើជីឡាវដែលបានញ៉ុកដោយសំឡីដើម្បីញែកទឹកអំបិលចេញពីខ្សាច់ ។ អំបិលនិងទឹកត្រូវបានច្រោះក្នុងកែវបេស៊ែរ ។

៤- យកកែវបេស៊ែរទឹកអំបិលដាក់លើបន្ទះសំណាញ់ដែកនៅលើទម្រជើងបី ។ ដាំទឹកអំបិលរហូតដល់ឃើញក្រាមអំបិល ។ ប្រើដង្កៀបដើម្បីចាប់យកកែវបេស៊ែចេញ ( មើលរូប) ។

<u>សង្កេត:</u> ខ្សាច់នៅជាប់លើច្រោះ ហើយទឹកអំបិលស្រក់ចូលទៅក្នុងកែវបេស៊ែរ ។

<u>សំនួរគន្លឹះ</u> : តើអ្នកអាចញែកអំបិលចេញពិខ្សាច់ដោយវិធីតែមួយបានដែរឬទេ? តើមានវិធីអ្វីខ្លះ? តើវិធីមួយណាជាលក្ខណ:រូប មួយណាជាលក្ខណ:គីមី?

<u>ការពន្យល</u> :ខ្សាច់មិនរលាយក្នុងទឹកទេ តែអំបិលរលាយក្នុងទឹក ។ ដូច្នេះអំបិលដែលរលាយអាចហូរកាត់សំឡីជាមួយទឹកបាន ។ ការដាំទឹកអំបិលអាចគឺបង្កើតជាក្រាមអំបិលក្នុងកែវបេស៊ែរ ។ ការច្រោះជាលក្ខណ:រូប និងការបង្ហួតជាលក្ខណ:គីមី ។



កែវបេស៊ែរ ចំនុះ 100 mL

**ពិសោធន៍ទី ១៣: ការធ្វើគ្រីស្តាល់ស្ករស** សៀវភៅសិស្សទំព័រ ១៦១

សៀវភៅសិស្សទំព័រ ១៦១

គោលបំណង : - សិស្សអាចធ្វើគ្រីស្តាល់ដោយប្រើវិធីរំហួត

-សិស្សអាចពន្យល់ពីដំណើរការនៃការរីកសាយនេះ

សំភារៈ និងសារធាតុ:

- ស្ករស
- កែវទឹក
- ខ្សែអំបោះ
- ចង្កឹះ
- ដបកាត់មាត់តូចមួយដែលមានគំនូសក្រិត
- ទឹក
- កែវអ៊ែកឡែនចំនុះ ១០០ mL
- ចង្កៀងអាល់កុល
- ទម្រជើងបី
- បន្ទះសំណាញ់ដែក
- ស្លាបព្រា

ដំណើរការពិសោធន៍:

១- ចាក់ស្ករសទៅក្នុងដបដ៏រកាត់មាត់រហូតដល់គំនូសរួចផ្ទេរទៅក្នុងកែវអ៊ែកឡែន។ ហើយធ្វើដូចនេះម្តងទៀត ( មានន័យថា ចាក់ស្ករស ២ដបកាត់មាត់ទៅក្នុងកែវ) ។

២- ចាក់ទឹកទៅក្នុងដបដ៏រដដែលរហូតដល់គំនូសក្រិត ហើយផ្ទេរវាទៅក្នុងកែវ អ៊ែកឡែនខាងលើដែលមានស្ករស និងប្រើចង្កឹះកូររហូតដល់ស្ករសរលាយខ្លះ។

៣- ដាក់កែវទឹកស្ករ លើបន្ទះសំណាញ់ដែក ដែលនៅលើទម្រជើងបី។ ប្រើចង្កៀង

អាល់កុល ដើម្បីដាំទឹកស្ករនេះអោយពុះ ដែលត្រូវចំណាយពេលប្រហែល ជា ១៥ នាទី ។

៤- នៅពេលដែលទឹកស្ករពុះហើយ ពន្លត់ចង្កៀងអាល់កុល បន្ទាប់មកចាក់ស្ករលាយ ស្បងផ្អែតនេះទៅក្នុងកែវមួយទៀតដោយទុកនូវ ស្ករដែលមិនទាន់រលាយអោយ នៅក្នុងកែវអ៊ែកឡែន ។ ហើយទុកសូលុយស្យុងនេះចំនួន ៥ នាទីឱ្យវាត្រជាក់ ។

៥- គួចខ្សែអំបោះឱ្យមានគំនួចធំល្មម ហើយចងវាជាមួយនឹងឈើដោយទុកឱ្យគំនួច នោះនៅឆ្ងាយពីឈើប្រមាណជា ៥ ទៅ ៦ សង់ទីម៉ែត (ដូចរូប)

៦- នៅពេលដែលសូលុយស្យុងស្ករនោះត្រជាក់ (បន្ទាប់ពីរង់ចាំរយៈពេល ៥ នាទី) ជ្រលក់គំនួចខ្សែនោះទៅក្នុងសូលុយស្យុងស្ករ ហើយដកវាចេញ ។ បន្ទាប់មក ប្រលាក់គំនួចដែលសើមជាមួយក្រាមស្ករស ។

៧- ទំលាក់គំនួចខ្សែដែលមានជាប់គ្រាប់ស្ករ និងដែលបានចងជាមួយចង្កឹះ ទៅក្នុង ទឹកស្ករវិញដោយថ្នមៗ ហើយដាក់ចង្កឹះឱ្យគងនឹងមាត់កែវ បន្ទាប់មកទុកវា រយៈពេល ២ ទៅ ៣ ថ្ងៃ ។

<u>អង្កេត</u> : ពីរបីថ្ងៃក្រោយមក អ្នកនឹងឃើញគ្រីស្តាល់ស្ករសដ៏ស្រស់ស្អាត ។ ចូរឧស្សាហ៍មើលវាជារៀងរាល់ថ្ងៃ ប៉ុន្តែហាមប៉ះ ឬដកខ្សែចេញ ។

គោលបំណង : តើល្បាយស្ករនិងទឹកជាល្បាយអ្វី? តើមានអ្វីកើតឡើងពេលសូលុយស្យុងហួត? ពេលកំណកក្រាមតើស្ករនៅក្នុងទឹកទៀតឬទេ? តើវិធីកំណកក្រាមនេះអាចញែកស្ករ ពីទឹកបានឬទេ? តើវាលក្ខណៈរូប ឬគីមី?

<u>ការពន្យល់</u> : នៅពេលដែលទឹកត្រូវបានរំហួតចេញសូលុយស្យុងផ្អែត ស្ករដែលមានបរិមាណលើស ទៅតោងជាប់ជាមួយនឹងដុំស្ករនៅលើគំនួចខ្សែ ហើយគ្រីស្តាល់នឹងកើតនៅជុំវិញដុំស្ករ ដែលនៅលើគំនួចនោះ ។ ពេលគ្រីស្តាល់កកើតមានឡើង ស្ករបានញែកចេញពីទឹក ។ ដោយសារល្បាយនេះស្មើសាច់ នោះការញែកត្រូវប្រព្រឹត្តទៅតាមវិធីគីមី ។






## ពិសោធន៍ទី១៤: គ្រូម៉ាតូក្រាហ្វីដីស

សៀវភៅឯកសារបំប៉ន ទំព័រ ១២៩
សៀវភៅឯកសារបំប៉ន ទំព័រ ១២៩

សៀវភៅសិស្សទំព័រ ១៦៣
សៀវភៅសិស្សទំព័រ ១៦៣

គោលបំណង : សិស្សអាចពន្យល់ពីដំណើរញែកល្បាយពណ៌ដែលកើតមាននៅលើដីស ។

សំភារៈ និងសារធាតុ:
- ដីស
- ទឹក
- លក្ខ័ពណ៌
- ដបកាត់មាត់តូចមួយ ឬកែវ
- ដែកលួស
- ចង្កឹះមុខស្រួច

ដំណើរការពិសោធន៍:

១- ប្រើចង្កឹះមុខស្រួចចុចលក្ខ័អាហារចំងាយប្រហែលមួយសង់ទីម៉ែត្រពីចុងនៃដីស ។

២- ចាក់ទឹកជំរៅប្រហែលកន្លះសង់ទីម៉ែតពីដបកាត់មាត់ ឬកែវ ។

៣- ដាក់បញ្ឈរដីសឡើង (ចងកំពូលវាជាមួយដែកលួសដើម្បីអោយដីសឈរត្រង់) នៅក្នុងកែវ ។

៤- លើដីសចេញពីទឹកពេលដែកទឹកជ្រាបជិតដល់កំពូលដីស ។

អង្កេត : សមាសភាគពណ៌ផ្សំរបស់លក្ខ័ពណ៌នឹងត្រូវបានជ្រាបឡើងលើដីស ហើយញែកចេញពីគ្នាយឺតៗ ។




សំនួរគន្លឹះ : តើល្បាយល័ក្ខពណ៌ជាល្បាយអ្វី? តើមានអ្វីកើតឡើងចំពោះល័ក្ខនៅលើដើមដីស? តើវិធីនេះជាលក្ខណៈរូប ឬគីមី?

ការពន្យល់ : សមាសភាគផ្សំនៃលក្ខ័ពណ៌ត្រូវបានញែកចេញពីគ្នា នៅពេលដែលទឹកជ្រាបឡើងតាម ដីស ។ ដោយសារល្បាយល័ក្ខពណ៌ស្មើសាច់ដូចនេះការញែកនេះមានលក្ខណៈគីមី ។សមាសភាគផ្សំនីមួ

យ៉ៗនៃលក្ខណៈពណិអាចផ្លាសទី នឹងមានចំងាយផ្សេងៗអាស្រ័យ លើសមាសភាគផ្សំនោះមាន ទំនោរចងភ្ជាប់ជាមួយជីស ឬក៏ទឹក។

# ផ្នែកទី ៣ ពិសោធន៍គីមីវិទ្យា ថ្នាក់ទី ៩

## Improved Basic Education in Cambodia Project (IBEC)

WORLD EDUCATION, INC

## មាតិកា


**ពិសោធន៍ទី ១ :** ទង្វើឧស្ម័នអុកស៊ីសែន

**ពិសោធន៍ទី ២ :** ចំហេះដែក

**ពិសោធន៍ទី ៣** : ចំហេះទ្បើន

**ពិសោធន៍ទី ៤ :** អត្តសញ្ញាណកម្មឧស្ម័នកាបូនិច

**ពិសោធន៍ទី ៥ :** ទង្វើសូលុយស្យុងទង់ដែងស៊ុលផាតកំហាប់ 1M

**ពិសោធន៍ទី ៦ :** អាលុយមីញ៉ូមក្លាយជាទង់ដែង (សម្រាប់គ្រូ)

**ពិសោធន៍ទី ៧ :** អាលុយមីញ៉ូមក្លាយជាទង់ដែង

**ពិសោធន៍ទី ៨ :** ប្រតិកម្មរវាង អាលុយមីញ៉ូម (Al)និង ស៊ូតកាត់ (NaOH)

ស្រទាប់ទាំងបីរបស់កំប៉ុងភេសជ្ជៈ (ការបង្ហាញរបស់គ្រូ)

**ពិសោធន៍ទី ៩** : ទង្វើឱ្យឃើញពីស្រទាប់ប្លាស្ទិចក្នុងកំប៉ុងភេសជ្ជៈ

**ពិសោធន៍ទី ១០** : ការហែកកំប៉ុង

**ពិសោធន៍ទី ១១** : ប៉េងប៉ោងមានឧស្ម័នអ៊ីដ្រូសែន

**ពិសោធន៍ទី ១២:** ការបង្ហាញពណ៌

**ពិសោធន៍ទី ១៣ :** រំលាយអំបិលក្នុងទឹក

**ពិសោធន៍ទី ១៤ :** កំបោរ និង ទឹក

**ពិសោធន៍ទី ១៥ :** អង្គធាតុចង្អុរពណ៌

**ពិសោធន៍ទី ១៦ :** ប្រតិកម្មអាស៊ីត-បាស : ប្រតិកម្មរវាង NaOH និង HCl

**ពិសោធន៍ទី ១៧ :** ប្រតិកម្មអាស៊ីត-បាស : ប្រតិកម្មរវាង សូដ្យូមប៊ីកាបូណាត និង ទឹកខ្មេះ

**ពិសោធន៍ទី ១៨ :** កំបោរ និង ទឹក ( ប្រើអង្គធាតុចង្អុលពណ៌)

**ពិសោធន៍ទី ១៩ :** ចំហេះស្ពាន់ធ័រ និង ការតេស្តវត្តមានស្ពាន់ធ័រឌីអុកស៊ីត ( អុកស៊ីតកម្ម-រេដុកម្ម)

**ពិសោធន៍ទី ២០ :** ទម្ងើសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត (NaOH) 5 M

**ពិសោធន៍ទី ២១ :** ការរំលាយ ស៊ូតកាត់ (NaOH)

**ពិសោធន៍ទី ២២ :** ប្រតិកម្មរវាង កាល់ស្យូមកាបូណាត ($CaCO_3$) ជាមួយ អាស៊ីតក្លរីឌ្រិច (HCl)

# ជំពូកទី ១

# អុកស៊ីសែន និង អ៊ីដ្រូសែន

**<u>ពិសោធន៍ទី ១</u> : <u>ទម្ងើអុកស៊ីសែន</u>**

សៀវភៅសិស្ស ទំព័រ ១១៨
សៀវភៅសិស្ស ទំព័រ ១១៨

<u>គោលបំណង</u> : សិស្សអាចផលិតអុកស៊ីសែនដោយលាយសារធាតុជាក់លាក់។

<u>សំភារៈ និង សារធាតុ :</u>

- កែវអឺកឡែនចំណុះ ១០០ មីលីលីត្រ (100 mL)
- ទឹកអុកស៊ីសែននេ ($H_2O_2$)
- ថ្មើមជ្រូក

<u>ដំណើរការពិសោធន៍ :</u> ១- ដាក់ថ្មើមមួយចំនិតតូច ( ប៉ុនម្រាមដៃ) ទៅក្នុងកែវអឺកឡែនចំណុះ ១០០ mL

២- បន្ថែមទឹកអុកស៊ីសែននេ ទៅលើថ្មើមក្នុងកែវ ( ដូចរូប)






<u>សំនួរគន្លឹះ</u> : តើមានអ្វីកើតចេញពីប្រតិកម្ម? តើឧស្ម័នអ្វីដែលកើតមាន?

<u>ការពន្យល់</u> :ពពុះបញ្ជាក់ពីឧស្ម័នកកើតមានឡើងពីប្រតិកម្ម ហើយឧស្ម័ននេះជាឧស្ម័នអុកស៊ីសែន។ រំលឹក ពិសោធន៍ ទី ២១ ក្នុងថ្នាក់ទី ៧ ទង្វើឧស្ម័នអុកស៊ីសែន។

**<u>ពិសោធន៍ទី ២</u> : <u>ចំហេះដែក</u>**

សៀវភៅសិស្ស ទំព័រ ១១៨

សៀវភៅគ្រូ ទំព័រ ១៦

សៀវភៅគ្រូ ទំព័រ ១៦

<u>គោលបំណង</u> : សិស្សអាចកំណត់ពីមូលហេតុដែលដែកឆេះដោយប្រើបញ្ញតិនៃចំហេះ និងលក្ខណៈរបស់អុកស៊ីសែន។

<u>សំភារៈ និង សារធាតុ :</u>

- ដែកដុសឆ្នាំង
- ចង្កៀងអាកុល
- ខ្សែលួស
- ឈើគូស
- កែវដែលមានអុកស៊ីសែន ( បានពីពិសោធន៍ទី ១)
- ធ្យូង

<u>ដំណើរការពិសោធន៍</u> : ១- ចងដែកដុសឆ្នាំងបន្តិចជាមួយនឹងធ្យូងមួយដុំតូចប៉ុនកូនដៃហើយចងជាមួយនឹងលួសដើម្បីងាយស្រួលកាន់

២- ដុតធ្យូងនិងដែកដុសឆ្នាំងរហូតដល់ធ្យូងឡើងក្រហម ហើយក្តៅ។

៣- ដាក់ដុំធ្យូងក្រហមក្តៅ ជាមួយដែកដុសឆ្នាំង ទៅក្នុងដបដែលមានផ្ទុកឧស្ម័នអុកស៊ីសែន។






<u>អង្កេត</u> : ដំបូងរងើកធ្យូងឆេះក្លាយជាអណ្តាតភ្លើងបន្ទាប់មកដែកដុសឆ្នាំក៏ឆេះក្លាយជាអណ្តាតភ្លើងដែរ ។

<u>សំនួរគន្លឹះ</u> : តើអ្វីធ្វើឱ្យដែកឆេះ?

<u>ការពន្យល់</u> : រងើកធ្យូងធ្វើឱ្យដែកក្តៅ ហើយ ដែកឆេះក្នុងកែវដែលមានអុកស៊ីសែន ។

**<u>រំលឹក</u>** : ទម្ងើឧស្ម័នអុកស៊ីសែន ក្នុងថ្នាក់ទី ៨ ពិសោធន៍ទី ៦

ការដុតកាបូន ក្នុងអុកស៊ីសែន ថ្នាក់ទី៧ ពិសោធន៍ទី ២១

**សមីការ :** $C + O_2 \longrightarrow CO_2$ និង $4Fe + 3O_2 \longrightarrow 2Fe_2O_3$

**<u>ចំហេះ អុកស៊ីតកម្ម_រេដុកម្ម</u>**

សៀវភៅឯកសារបំប៉ន ទំព័រ ១០
សៀវភៅឯកសារបំប៉ន ទំព័រ ១០

**<u>ពិសោធន៍ទី ៣ : ចំហេះទៀន</u>**

<u>គោលបំណង</u> : សិស្សអាចពន្យល់ពីមូលហេតុដែលធ្វើឱ្យទៀនឆេះដោយប្រើបញ្ញតិនៃចំហេះ និងលក្ខណៈរបស់អុកស៊ីសែន ។

<u>សំភារៈ និង សារធាតុ :</u>

- ទៀនតូចមួយ
- គំរបដបទឹក
- ចានជ័រដាក់ទឹកធំមួយ
- ឈើគូស
- ទឹក
- កែវ

<u>ដំណើរការពិសោធន៍ :</u> ១- ដាក់ទៀនទៅលើគំរបដបទឹក

២- ដុតទៀន បន្ទាប់មក ដាក់គំរបដបដែលមានទៀននោះបណ្តែតទៅក្នុងទឹកដែលនៅក្នុងចានជ័រ ។

៣- ប្រើកែវគ្របពីលើទៀនដែលនៅលើទឹក ហើយ មើលកំរិតទឹកនៅក្នុងកែវដែលមានទៀននៅខាងក្នុង ។




អង្កេត : បន្ទាប់ពីទៀនបានរលត់ កំពស់ទឹកក្នុងកែវកើនឡើង ។

សំនួរគន្លឹះ : តើទៀនឆេះនៅក្នុងកែវបានដោយសារឧស្ម័នអ្វី? តើមានអ្វីកើតឡើងចំពោះទៀនពេលឧស្ម័ននៅក្នុងកែវត្រូវបានប្រើអស់? ហេតុអ្វីបានជាកំពស់ទឹកក្នុងកែវកើនឡើង?

ការពន្យល់ : ទៀនប្រើប្រាស់អុកស៊ីសែន ដូចនេះ ទឹកឡើងនៅក្នុងកែវទៅជំនួសអុកស៊ីសែនដែលបានប្រើប្រាស់អស់ ។ អុកស៊ីសែននៅក្នុងកែវត្រូវបានប្រើអស់ ហើយសំពាធនៅក្នុងកែវត្រូវថយចុះ ជាហេតុធ្វើឱ្យសំពាធខាងក្រៅដែលខ្លាំងជាងរុញទឹកពីខាងក្រៅ ហើយធ្វើឱ្យកំពស់ទឹកក្នុងកែវកើនឡើង ។

**ពិសោធន៍ទី ៤ : អត្តសញ្ញាណកម្ម ឧស្ម័នកាបូនិច**

សៀវភៅសិស្ស ទំព័រ ១២៤
សៀវភៅសិស្ស ទំព័រ ១២៤

គោលបំណង : សិស្សអាចអត្តសញ្ញាណឧស្ម័នកាបូនិចដោយប្រើទឹកកំបោរថ្លា ។

សំភារៈ និង សារធាតុ :

- ទៀន
- កែវ
- ទឹកកំបោរថ្លា
- ឈើគូស

ដំណើរការពិសោធន៍ :

១- ដុតទៀនដោយប្រើឈើគូស ។

២- ប្រើកែវគ្របពីលើភ្លើងទៀនរហូតដល់ទៀនរលត់ ។

៣- ដាក់កែវលើតុ ហើយចាក់ទឹកកំបោរថ្លាប្រហែលជា ២ រឺ៣ សង់ទីម៉ែត ទៅក្នុងកែវនោះ ។

៤- ក្រឡុកទឹកកំបោរថ្លាដែលនៅក្នុងកែវនោះ ១ ទៅ ២នាទី ។






អង្កេត : ទឹកកំបោរថ្លាក្លាយទៅជាល្អក់ ។

សំនួរគន្លឹះ : តើឧស្ម័នអ្វីដែលអ្នកគិតថាធ្វើឱ្យទឹកកំបោរថ្លាប្រែជាល្អក់? តើវាបានមកពីណា?

ការពន្យល់ : ទឹកកំបោរថ្លា ត្រូវបានគេប្រើដើម្បីធ្វើតេស្តរកឧស្ម័នកាបូនិច ។ ដូចនេះទឹកកំបោរប្រែរជាល្អក់ នៅពេលដែលឧស្ម័នកាបូនិចកកើតពីចំហេះទាន រលាយចូលក្នុងទឹកកំបោរថ្លា ។

**រំលឹក:** ទង្វើអុកស៊ីសែន ក្នុងថ្នាក់ទី ៨ ពិសោធន៍ទី ៦
ចំហេះកាបូន ក្នុងថ្នាក់ទី ៨ ពិសោធន៍ទី ៧
ចំហេះដែក ក្នុងថ្នាក់ទី ៩ ពិសោធន៍ទី ២

**សមីការ :**

$$2H_2O_2 \rightarrow 2H_2O + O_2\uparrow$$

$$C + O_2 \rightarrow CO_2\uparrow$$

$$4Fe + 3O_2 \rightarrow 2Fe_2O_3$$

**ចំនាំ :** ប្រតិកម្មអុកស៊ីដូ-រេដុកម្ម អាចត្រូវបានកត់សិស្សអាចសំគាល់ដោយមានការផ្លាស់ប្តូរពី សមាសធាតុ ទៅជាធាតុរី ធាតុទៅជាសមាសធាតុ ។ ( សម្រាប់ គីមីថ្នាក់វិទ្យាល័យប្រធានបទនេះគឺត្រូវបាន ពន្យល់តាមលក្ខណ:ស៊ីជំរៅជាងនេះ ) ។

## ពិសោធន៍ទី ៩ : ទង្វើសូលុយស្យុងទង់ដែងក្លរួដែលមានកំហាប់១ម៉ូល

គោលបំណង : សិស្សអាចធ្វើសូលុយស្យុងទង់ដែងក្លរួកំហាប់មួយម៉ូល ( រៀបចំសំរាប់ពិសោធន៍ទី ៦ និងទី៧)

សំភារ: និង សារធាតុ :

- ក្រាមទង់ដែងស៊ុលផាតពណ៌ខៀវ( សាច់ដូខៀវ)

មិនមានឯកសារយោងនៅក្នុងសៀវភៅ អត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យ សិស្សយល់ ។

- ដបសំរាប់ដាក់សូលុយស្យុង
- ស្លាព្រា
- ជីឡាវ
- ទឹក

ដំណើរការពិសោធន៍ : ១- ដាក់ក្រាមទងដែងស៊ុលផាតពណ៌ខៀវដល់គំនូសទីមួយ នៅក្នុងដបធំមួយ ។

២- បន្ថែមទឹកដល់គំនូសទី២ រួចក្រឡុកដបរហូតក្រាមនោះរលាយអស់ ។

៣- បន្ថែមអំបិលមួយស្លាព្រាចូលទៅក្នុងដប ហើយក្រឡុកអោយអំបិលរលាយ ។

៤- បន្ថែមទឹកដល់គំនូសទី៣ ហើយក្រឡុកអោយចូលគ្នា ។

**ពិសោធន៍ទី ៦ : អាលុយមីញ៉ូមក្លាយជាទង់ដែង ( គ្រូបង្ហាញ)**[1]

គោលបំណង : សិស្សអាចអត្តសញ្ញាណពីប្រតិកម្មអុកស៊ីតកម្ម-រេដុកម្ម ( ការជំនួសអាលុយមីញ៉ូមដោយទង់ដែង) ។

មិនមានឯកសាយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

សារធាតុ និង សំភារៈ

- អាលុយមីញ៉ូមដែលពូតជាបាល់ចំនួន២ ( មួយប៉ុនបាល់កីឡាតេននីស និងមួយទៀតទំហំស្មើពាក់កណ្តាលបាល់ទីមួយ)
- កែវបេស៊ែចំណុះ ៥០០ មីលីលីត្រ ចំនួន២
- ទឹក
- សុលុយស្យុងទង់ដែងក្លរួ កំហាប់ ១ម៉ូល

ដំណើរការពិសោធន៍១: ១- ចាក់សូលុយស្យុងទង់ដែងក្លរួ $CuCl_2$ ដែលមានកំហាប់ ១ម៉ូលចូលក្នុងកែវបេស៊ែដែលមាន ចំនុះ៥០០មីលីលីត្រត្រឹមពាក់កណ្តាល ។

២-ដាក់អាលុយមីញ៉ូមដែលពូតជាបាល់ចំនួនមួយប៉ុនបាល់កីឡាតេននេះចូលទៅក្នុងកែវ




[1] ការបង្ហាញនេះសំរាប់តែគ្រូទេ ដោយសារប្រតិម្មនេះទាមទាឱ្យមានការរៀបចំទុកមុន ហើយប្រតិកម្មនេះបញ្ចេញកំដៅ និងពេលយូរ( ១ថ្ងៃ)

អង្កេត : សូលុយស្យុងឡើងក្ដៅ ហើយប្រែជាគ្មានពណ៌នៅថ្ងៃបន្ទាប់ យើងនឹងឃើញទង់ដែងជាច្រើន និង អាលុយមីញ៉ូមដែលមិនទាន់មានប្រតិកម្មនៅក្នុងកែវ ។

សំនួរគន្លឹះ : តើមានអ្វីមកជំនួសអាលុយមីញ៉ូម? តើអ្នកអាចដឹងដោយរបៀបណា? តើទង់ដែងកើតមកពីណា?

ការពន្យល : អាលុយមីញ៉ូមបានចូលទៅជំនួសទង់ដែងនៅក្នុងសូលុយស្យុងទង់ដែងក្លរួ ដូចនេះទង់ដែងក៏បានបង្កើតឡើងមានពណ៌ត្នោត ។ អាលុយមីញ៉ូមមានបរិមាណលើស ដូចនេះវានៅសល់ព្រោះសូលុយស្យុងទង់ដែងក្លរួមានប្រតិកម្មអស់ ហើយសូលុយស្យុងប្រែជាគ្មានពណ៌ ។

**សមីការប្រតិកម្ម:** $2Al\ (s) + 3CuCl\ (aq) \longrightarrow 2AlCl_3\ (aq) + 3Cu\ (s)$

ដំណើរការពិសោធន៍ទី២: ១- ចាក់សូលុយស្យុងទង់ដែងក្លរួដែលមានកំហាប់ ១ម៉ូលចូលក្នុងកែវបេស៊ែដែលមានចំនុះ ៥០០មីលីលីត្រត្រឹមពាក់កណ្ដាល ។

២- ដាក់អាលុយមីញ៉ូមដែលពូតជាបាល់ចំនួនមួយមានទំហំប្រហែលស្មើពាក់កណ្ដាលកូនបាល់ ។




អង្កេត : សូលុយស្យុងឡើងក្ដៅ ហើយពណ៌ខៀវនៅតែបន្សល់នៅថ្ងៃបន្ទាប់ យើងនឹងឃើញទង់ដែង ប៉ុន្តែមិនមានអាលុយមីញ៉ូមនៅក្នុងកែវទៀតទេ ។

ការពន្យល់ : អាលុយមីញ៉ូមបានចូលទៅជំនួសទង់ដែងនៅក្នុងសូលុយស្យុងទង់ដែងក្លរួ ដូចនេះទង់ដែងក៏បានបង្កើតឡើងមានពណ៌ត្នោត ។ សូលុយស្យុងទង់ដែងក្លរួ មានបរិមាណលើសហើយអាលុយមីញ៉ូមចូលប្រតិកម្មអស់ដូចនេះពណ៌ខៀវនៃសូលុយស្យុងទង់ដែងក្លរួនៅតែមាន ។

**ពិសោធន៍ទី៧ : អាលុយមីញ៉ូមបាត់ កកើតនូវទង់ដែង**


សៀវភៅសិស្ស ទំព័រ ១២៦

គោលបំណង : សិស្សអាចអត្តសញ្ញាណពីប្រតិកម្មអុកស៊ីតកម្ម-រេដុកម្ម (ការជំនួសអាលុយមីញ៉ូមដោយទង់ដែង) ។

សំភារៈ និង សារធាតុ :

- អាលុយមីញ៉ូមមួយបន្ទះតូច
- បំពងសាក និង ដង្កៀបបំពងសាក
- សូលុយស្យុងទង់ដែងក្លរួដែលមានកំហាប់១ម៉ូល

ដំណើរការពិសោធន៍: ១- ដាក់អាលុយមីញ៉ូមមួយដុំតូចចូលទៅក្នុងបំពងសាក ។

២- ចាក់សូលុយស្យុងទង់ដែងក្លរួប្រហែលជា ១ភាគ ៣ នៃបំពង់សាកចូលទៅក្នុងបំពងសាក ។




សំនួរគន្លឹះ : តើមានអ្វីមកជំនួសអាលុយមីញ៉ូម? តើអ្នកអាចដឹងដោយរបៀបណា? តើទង់ដែងកើតមកពីណា?

អង្កេត : ២ ឺ ៣នាទី ក្រោយមក អាលុយមីញ៉ូមបានគ្របដណ្តប់ដោយទង់ដែងដែលមានពណ៌ត្នោត ។

**ពិសោធន៍ទី ៨ : អាលុយមីញ៉ូម (Al) មានប្រតិកម្មជាមួយសូលុយស្យុងស៊ូត (NaOH)**

គោលបំណង : សិស្សអាចបន្សល់ពីដែលកើតឡើងពីប្រតិកម្មរវាង អាលុយមីញ៉ូម (Al) មានប្រតិកម្មជាមួយសូលុយស្យុងស៊ូត (NaOH)

សំភារៈ និង សារធាតុ:

សៀវភៅសិស្ស ទំព័រ ១៣២, ១៣៦
សៀវភៅគ្រូ ទំព័រ ៣៥,៣៦

- សូលុយស្យុងស៊ូតកំហាប់ ៥ ម៉ូល
- អាលុយមីញ៉ូម
- ឈើគូស
- បំពងសាក និង ដង្កៀបបំពងសាក

- ចង្កឹះឈើមួយ

ដំណើរការពិសោធន៍ : ១- ចាក់សូលុយស្យុងស៊ូតចូលដល់ពាក់កណ្ដាលបំពង់សាក ។

២- បន្ថែមអាលុយមីញ៉ូមមួយតូចទៅក្នុងបំពងសាក ។

៣- ដុតចង្កឹះឈើ ហើយដាក់វាលើមាត់បំពង់សាកហើយតេស្ដរកឧស្ម័ន ។

អង្កេត : បំពងសាកឡើងក្ដៅ ។

សំនួរគន្លឹះ : តើអ្នកសង្កេតឃើញមានអ្វីកើតពីប្រតិកម្ម? តើអ្នកគិតថាមានឧស្ម័នអ្វីកើតចេញពីប្រតិកម្ម?

ការពន្យល : ប្រតិកម្មមួយចំនួនបញ្ចេញកំដៅយ៉ាងខ្លាំង ។ អណ្ដាតភ្លើង ជាមួយសំលេង ប៉ប់ បញ្ជាក់ថាឧស្ម័នដែលកកើតជា ឧស្ម័នអ៊ីដ្រូសែន ។

**ប្រតិកម្ម :**

$$2Al\,(s) + 6NaOH\,(aq) \longrightarrow 3H_2\,(g) + 2Na_3AlO_3\,(aq)$$

$$2Al\,(s) + 2NaOH\,(aq) \longrightarrow H_2\,(g) + 2NaAlO_2\,(aq)$$

**ពិសោធន៍ទី ១០ : ការធ្វើឱ្យឃើញស្រទាប់ប្លាស្ទិចនៅក្នុងកំប៉ុងសូដា ( គ្រូបង្ហាញ)**

គោលបំណង : - សិស្សអាចកំណត់ពីសមាសធាតុផ្សំរបស់សំបកកំប៉ុង

- សិស្សអាចយល់ពីប្រយោជន៍របស់ស្រទាប់ប្លាស្ទិចនៅខាងក្នុងកំប៉ុងភេសជ្ជះ

សំភារៈ និង សារធាតុ :

- កំប៉ុងសូដាមួយ
- ក្រដាសខាត់
- ស្កត់បិទ
- ខ្លាញ់គោ
- កែវបេស៊ែរ ចំណុះ ៥០០ មីលីលីត្រ
- ទម្រជើងបី
- ខ្សែ
- ចង្កឹះ
- ចានដ៏រធំមួយ
- សូលុយស្យុងស៊ូតដែលមានកំហាប់ ៥ ម៉ូល

មិនមានឯកសាយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

ដំណើរការពិសោធន៍ : ១- បិទស្កត់ខាងលើ និង ខាងក្រោម នៃកំប៉ុងសូដាទទេ ។

២- ខាត់ផ្ទៃកកណ្ដាលនៃកំប៉ុងរហូតដល់ឃើញអាលុយមីញ៉ូម ។

៣- លាបខ្លាញ់គោពីលើកន្លែងដែលបិតស្កត់

៤- ចាក់ទឹកចូលកំប៉ុងឱ្យពេញ ។

៥- ដាក់កំប៉ុងចូលក្នុងកែវបេស៊ែ —យកខ្សែចងក្រវ៉ាលកំប៉ុង ហើយចងជាមួយចង្កឹះ ដោយឱ្យចង្កឹះតងលើជំទុលជើងបីដូចនេះអ្នកអាចព្យួរវាបាន ហើយ នឹងងាយស្រួល ដកចេញនៅពេលឃើញប្លាស្ទិច ។ (មើលរូប)

៦- **ចំណាំ ត្រូវធ្វើនៅក្នុងទូរស្រូបកំដៅ រឺ នៅខាងក្រៅ** (ព្រោះមានក្លិនអាក្រក់ ក្តៅ និងកាត់ស៊ី) ដាក់អ្វីដែលបានរៀបចំខាងលើនេះទៅក្នុងចានជ័រធំហើយបន្ថែម សូលុយស្យុងសូ៊តរហូតជិតពេញកែវបេស៊ែរ ។

៧- ពិនិត្យមើលរៀងរាល់ ១០នាទីម្តង ប្រសិនបើឃើញថងប្លាស្ទិច លើកវាដោយ ប្រយ័ត្ន ។( ត្រូវចំនាយពេលមិនដល់១ម៉ោងទេ) ។

៨- លើកកំប៉ុងឡើងដោយប្រុងប្រយ័ត្ននៅពេលដែលឃើញប្លាស្ទិច ហើយដាក់វាចុះ ដោយថ្នមៗ និង លាងសំអាតក្នុងចានជ័រធំ ។

៩- យកចានធំជាមួយកំប៉ុងទៅកន្លែងមានទឹកច្រើន និង លាងសំអាតថ្នមៗ ។

១០- ចាក់ទឹកចេញពីកំប៉ុងដោយប្រយ័ត្ន ។

១១- ដាក់កំប៉ុងក្នុងដបប្លាស្ទិចដែលមានចំនុះ២ លីត្រដែលបានកាត់ឱ្យមានបង្អួច ។ ព្យួរ វាទៅក្នុងដបប្លាស្ទិចនោះ ។

<u>**បង្ហាញថង់ប្លាស្ទិចនៅក្នុងកំប៉ុងសូដា ( គ្រូបង្ហាញ)**</u>




កំប៉ុង Coca Cola



ស្រទាប់អាលុយមីញ៉ូម
(បន្ទាប់ពីខាត់រួច)



ស្រទាប់ប្លាស្ទិចនៅខាងក្នុង
(បន្ទាប់ពីដាក់ក្នុងសូ៊ត)

<u>ការពន្យល់:</u> អាលុយមីញ៉ូមអាចមានប្រតិកម្មជាមួយអាស៊ីតភេសជ្ជៈ ដូច្នេះទើបបានមានស្រទាប់ប្លាស្ទិច ការពារពីប្រតិកម្មដែលកើតមានឡើង ។

**ពិសោធន៍ទី ១១ : ការកាច់កំប៉ុង**

សៀវភៅសិស្ស ទំព័រ ១២៦
សៀវភៅសិស្ស ទំព័រ ១២៦

គោលបំណង : - សិស្សអាចពន្យល់ពីប្រតិកម្មដែលកើតមានរវាងអាលុយមីញ៉ូម និងទង់ដែងក្លរួពេលដែលស្រទាប់ប្លាស្ទិចខាងក្នុងត្រូវបានកាត់ផ្តាច់

- សិស្សអាចពន្យលពីមូហេតុដែលធ្វើកំប៉ុងងាយកាច់បន្ទាប់ពីចាក់សូលុយស្យុងទង់ដែងក្លរួចូល ។

សំភារៈ និង សារធាតុៈ

- កន្ត្រៃ
- កំប៉ុងសូដាទទេមួយ
- សូលុយស្យុងទង់ដែងក្លរួកំហាប់១ម៉ូល

ដំណើរការពិសោធន៍ : ១- ដោយប្រើចុងកន្ត្រៃ ឆូតខាងក្នុងកំប៉ុងជារង្វង់ត្រង់កណ្តាលដើម្បីកាត់ប្លាស្ទិច

២- ចាក់សូលុយស្យុងទង់ដែងក្លរួដែលមានកំហាប់១ម៉ូលរហូតដល់ហួសកន្លែងឆូត រួចទុករយៈពេល ៣ ទៅ ៤នាទី ។

៣- ចាក់សូលុយស្យុងចេញពីកំប៉ុងវិញ រួចរក្សាវាទុកប្រើម្តងទៀត ។

៤- កាច់កំប៉ុង ( រកមើលទង់ដែងកកើតនៅកន្លែងដែលកាច់) ។

អង្កេត : កំប៉ុងដាច់យ៉ាងស្រួល ដោយគ្រាន់តែទាញវី មួលបន្តិច ។

សំនួរគន្លឹះ : បន្ទាប់ពីកាត់ប្លាស្ទិច និងចាក់សូលុយស្យុងទង់ដែងក្លរួ ចូលទៅក្នុងកំប៉ុង នេះហើយ តើកំប៉ុងនេះងាយកាច់ឬទេ? ហេតុអ្វីបាន់កំប៉ុងនេះងាយកាច់?

ការពន្យល់ : នៅពេលដែលឆូតដាច់ប្លាស្ទិច អាលុយមីញ៉ូមអាចមានប្រតិកម្មជាមួយសូលុយស្យុងទង់ដែងក្លរួ ។ ដូចនេះ មានតែសំបកថ្នាំលាបខាងក្រៅទេដែលនៅសល់ ដូចនេះ កំប៉ុងត្រូវបានកាច់យ៉ាងងាយស្រួល ។

**សមីការតាងប្រតិកម្ម :** $2Al\,(s) + 3CuCl_2\,(aq) \rightarrow 2AlCl_3\,(aq) + 3Cu\,(s)$

**ឧស្ម័នអ៊ីដ្រូសែន**

**លក្ខណៈឧស្ម័នអ៊ីដ្រូសែន**

សៀវភៅសិស្ស ទំព័រ ១៣៥
សៀវភៅសិស្ស ទំព័រ ១៣៥

**ពិសោធន៍ទី ១២ : ផ្ទុះប៉េងប៉ោងដោយឧស្ម័នអ៊ីដ្រូសែន**

គោលបំណង : សិស្សអាចកំណត់ពីភាពខុសគ្នារវាងឧស្ម័នអ៊ីដ្រូសែន និងខ្យល់ដោយផ្អែកលើបញ្ញតិនៃដង់ស៊ីតេរបស់វា ។

សំភារៈ និង សារធាតុ :

- ប៉េងប៉ោងទំហំមធ្យមចំនួនពីរ

- ដបជ័រកាត់មាត់ចំនួនពីរ
- សូលុយស្យុងស៊ូតកំហាប់ ២.៥ម៉ូល
- កែវអ៊ែកឡែនចំនុះ ១០០មីលីលីត្រ

ដំណើរការពិសោធន៍ :

១- យកបន្ទះអាលុយមីញ៉ូមប៉ុនមេដៃ ហែក និង បត់វាឱ្យដូចបាល់តូចៗប៉ុនមេដៃ

២- ចាក់សូលុយស្យុងស៊ូតដោយប្រុងប្រយ័ត្នប្រហែលជា៤០មីលីលីត្រចូលទៅក្នុងកែវអ៊ែកឡែន

៣- ដាក់ដុំបាល់អាលុយមីញ៉ូមតូចៗនោះទៅក្នុងកែវអ៊ែកឡែន

៤- ភ្ជាប់ប៉េងប៉ោង ទៅនឹងមាត់កែវ ហើយទុករយៈពេលប្រហែលជា ៥ នាទី

៥- យកប៉េងប៉ោងចេញ ហើយគួចមាត់វា ។

៦- ផ្លុំខ្យល់ចូលប៉េងប៉ោងមួយទៀតឱ្យប៉ុនប៉េងប៉ោងមុន ។

៧- កាន់ប៉េងប៉ោងទាំងពីរឱ្យស្មើគ្នា ហើយទំលាក់ព្រមគ្នានៅពេលតែមួយ ។




អង្កេត : ប៉េងប៉ោងដែលមានខ្យល់ធ្លាក់មកក្រោមមុនប៉េងប៉ោងដែលមានអ៊ីដ្រូសែន ។

សំនួរគន្លឹះ : ហេតុអ្វីប៉េងប៉ោងដែលផ្ទុកអ៊ីដ្រូសែនធ្លាក់យឺតជាងប៉េងប៉ោងដែលមានខ្យល់?

ការពន្យល់ : អ៊ីដ្រូសែនមានដង់ស៊ីតេទាបជាងខ្យល់ ។

# ជំពូកទី ២

# ទឹក និង សូលុយស្យុង

**សូលុយស្យុង**

**ពិសោធន៍ ១៣ :ការបង្ហាញពណ៌** (Color show)

សៀវភៅសិស្ស ទំព័រ ១៤៤
សៀវភៅសិស្ស ទំព័រ ១៤៤

គោលបំណង : សិស្សអាចពន្យល់ពីមូលហេតុដែលសូលុយស្យុងល័ក្ខពណ៌រលាយក្នុងទឹក និងមិនរលាយក្នុងប្រេង។

សំភារះ និង សារធាតុ

- ប្រេងឆា
- ដបកាត់តូចពីរ
- ល័ក្ខសំរាប់ដាក់អាហារបីពណ៌ខុសៗគ្នា
- ទឹក
- ទុយោ

ដំណើរការពិសោធន៍: ១- ចាក់ប្រេងប្រហែល ១ cm ទៅក្នុងដបកាត់តូចមួយ

២- បន្តក់ល័ក្ខបីតំនក់ក្នុងមួយពណ៌ៗចូលទៅក្នុងប្រេងដោយប្រើទុយោ

៣- ក្រឡុកល្បាយប្រេងល័ក្ខដែលនៅក្នុងដបដោយថ្នមៗ

៤- ចាក់ទឹកទៅក្នុងដបកាត់តូចមួយផ្សេងទៀតរហូតដល់ជិតពេញ

៥- ចាក់ល្បាយប្រេងល័ក្ខទៅលើផ្ទៃទឹក ហើយ ពិនិត្យមើលពណ៌

អង្កេត : ស្រទាប់ប្រេងស្ថិតនៅលើស្រទាប់ទឹក ។ ល័ក្ខឆ្លងកាត់ស្រទាប់ប្រេងខាងលើជាតំនត់តូចៗ ហើយ រលាយចូលទៅក្នុងទឹកហាក់ដូចជា ទឹកផ្កាឈូកដែលមានពណ៌ ។

សំនួរគន្លឹះ : តើល័ក្ខ និងប្រេងរលាយចូលគ្នាឬទេ? តើប្រេង និងល័ក្ខមានទម្រង់ដូចគ្នាឬទេ? តើល័ក្ខ និងទឹកមានទម្រង់ដូចគ្នាឬទេ?

ការពន្យល់ : ប្រេងមានដង់ស៊ីតេតូចជាងទឹក ដូច្នេះវាអណ្តែតនៅលើទឹក ។ ប្រេង និង ទឹក មិនរលាយចូលគ្នាទេ ពីព្រោះ វាមានទម្រង់គីមីផ្សេងគ្នា ។ ល័ក្ខមានទម្រង់គីមីស្រដៀងនឹងទំរង់គីមីទឹក ដូច្នេះវាឆ្លងកាត់ស្រទាប់ប្រេង ហើយទៅរលាយជាមួយទឹក ។

**រំលឹក:** រលកក្នុងដប ថ្នាក់ទី ៧ — ពិសោធន៍ទី១៨

## ពិសោធន៍ទី ១៤ : ការរលាយអំបិលក្នុងទឹក

សៀវភៅសិស្ស ទំព័រ ១៥៥
សៀវភៅសិស្ស ទំព័រ ១៥៥

គោលបំណង : សិស្សអាចកំណត់ពីលក្ខណៈរបស់ល្បាយស្មើសាច់ដោយផ្អែកលើការរំលាយអំបិល ដោយទឹក។

សំភារៈ និង សារធាតុ

- ទឹក
- អំបិល
- ដបកាត់តូចមួយ
- កំណាត់ឈើ
- ស្លាបព្រាតូចមួយ

ដំណើរការពិសោធន៍: ១- ចាក់ទឹកចូលទៅក្នុងដបកាត់តូចមួយ

២- ដាក់អំបិលមួយស្លាបព្រាពេញចូលទៅក្នុងទឹក ហើយ យកឈើកូរវា ។




អង្កេត : អំបិលរលាយក្នុងទឹក

<u>សំនួរគន្លឹះ</u> : តើមានអ្វីកើតឡើងចំពោះអំបិលពេលអ្នកថែមទឹកចូល?

តើអ្នកអាចឃើញអំបិលនៅក្នុងទឹកទៀតទេ? តើល្បាយនេះជាល្បាយអ្វី?

<u>ការពន្យល់</u> : អំបិល គឺជាអង្គធាតុដែលអាចរលាយក្នុងទឹកបាន។ គេមិនអាចញែកថាមានអំបិលនៅផ្នែកណាក្នុងទឹកបានទៀតហើយ។ ល្បាយនេះគឺជាល្បាយស្មើសាច់។

**<u>ពិសោធន៍ទី១៥ : កាល់ស្យូមអុកស៊ីត (CaO) និង ទឹក</u>** សៀវភៅសិស្ស ទំព័រ ១៥៥

សៀវភៅសិស្ស ទំព័រ ១៥៥

<u>គោលបំណង</u> : សិស្សអាចកំណត់ពីលក្ខណៈរបស់ល្បាយមិនស្មើសាច់ដោយផ្អែកលើការរំលាយកំបោរដោយទឹក។

<u>សំភារៈ និង សារធាតុ:</u>

- កាល់ស្យូមអុកស៊ីតរឹង( កំបោរ)
- កែវ
- ឈើសម្រាប់កូរ

<u>ដំណើរការពិសោធន៍:</u> ១- ដាក់កាល់ស្យូមអុកស៊ីតចូលទៅក្នុងកែវ

២- បន្ថែមទឹកចូលទៅក្នុងដបកែវ ហើយកូរវា។



$Ca(OH)_2$ អង្គធាតុរលាយតិច

<u>អង្កេត:</u> កករនឹងលេចឡើងក្នុងទឹក។

<u>សំនួរគន្លឹះ</u> : តើមានអ្វីកើតឡើងពេលអ្នកដាក់កំបោរចូលក្នុងទឹក? តើអ្នកសង្កេតឃើញមាន កាល់ស្យូមអ៊ីដ្រុកស៊ីត [$Ca(OH)_2$]ដែលមិនរលាយឬទេ? តើល្បាយនេះជាល្បាយអ្វី?

<u>ការពន្យល់</u> :កាល់ស្យូមអុកស៊ីតមានប្រតិកម្មជាមួយទឹកបង្កើតបានជាអង្គធាតុមួយ គឺកាល់ស្យូមអ៊ីដ្រុកស៊ីត [$Ca(OH)_2$] ដែលរលាយតិចក្នុងទឹក ហើយល្បាយដែលទទួលបានជាល្បាយមិនស្មើសាច់។

**<u>ប្រតិកម្មគីមី:</u>** $CaO + H_2O \rightarrow Ca(OH)_2\downarrow$

# ជំពូកទី ៣

# អុកស៊ីត អាស៊ីត និង បាស

**ពិសោធន៍ទី ១៦ : អង្គធាតុចង្អុលពណ៌**

សៀវភៅសិស្ស ទំព័រ ១៧៦,១៨០
សៀវភៅគ្រូ ទំព័រ ៩៧
សៀវភៅឯកសារបំប៉ន ទំព័រ ១៣៤

គោលបំណង : សិស្សអាចពន្យល់ពីអ្វីជាអង្គធាតុចង្អុរពណ៌ និងការប្រើប្រាស់វា ក្នុងការកំណត់រវាងសូលុយស្យុងអាស៊ីត និងបាស ។

សំភារៈនិងសារធាតុ

- ដបប្លាស្ទិចកាត់មាត់ធំៗចំនួនបី
- ទឹក
- អង្គធាតុចង្អុរពណ៌ ( ទឹកស្លែក្តោបពណ៌ស្វាយ)
- ដបទឹកសុទ្ធទទេមួយ
- សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ៥ ម៉ូល
- អាស៊ីតក្លរីដ្រិច (HCl) ( ទឹកលាងបង្គន់)

**ការរៀបចំ ( ទឹកស្លែក្តោបពណ៌ស្វាយ)**

កាត់ស្ពៃក្តោបពណ៌ស្វាយជាចំណែកតូចៗ ។ ដាក់ចំណែកតូចៗនោះចូលទៅក្នុងឆ្នាំងដែលមានទឹក បន្ទាប់មក យកវាទៅដាំឱ្យពុះ ហើយ ចាក់យកតែទឹកស្ពៃក្តោបពណ៌ស្វាយចូលក្នុងដបទឹកសុទ្ធទទេ ។

ដំណើរការពិសោធន៍: ១- ចាក់ទឹកចូលក្នុងដបកាត់មាត់លេខ ១ រហូតដល់គំនូសក្រិតទី១រួចបន្ថែមស៊ូតដល់គំនូសក្រិតទី២ ។

២- ចាក់ទឹកចូលក្នុងដបកាត់មាត់លេខ ២ រហូតដល់គំនូសក្រិតទី១ រួចបន្ថែម HCl ដល់គំនូសក្រិតទី២ ។

៣- ចាក់ទឹកចូលក្នុងដបកាត់មាត់លេខ ៣ រហូតដល់គំនូសក្រិត ។

៤-បន្ថែមទឹកស្ពៃក្តោបពណ៌ស្វាយបួនស្លាបព្រាបាយចូលទៅក្នុងដបកាត់មាត់ទាំងបីខាងលើហើយកូរវានិង ពិនិត្យមើលពណ៌ ។ ( ចូរមើលរូបភាព)




អង្កេត : ទឹកនៅក្នុងដបកាត់មាត់លេខ ៣ ប្រែពណ៌ទៅជាពណ៌ខៀវ រីឯ ដបលេខ ២ ដែលមានទឹក និង អាស៊ីតក្លរីឌ្រិច ប្រែជាពណ៌ផ្កាឈូក ប៉ុន្តែ ចំពោះដបលេខ ១ ដែលមានទឹក និង សូដ្យូមអ៊ីដ្រុកស៊ីត ប្រែជាពណ៌បៃតង-លឿង ។

សំនួរគន្លឹះ : តើគេប្រើទឹកស្ពៃក្តោបស្វាយដើម្បីអ្វី? តើវាមានពណ៌ដូចម្តេច នៅក្នុងទឹក អាស៊ីត និងបាស?

ការពន្យល់ : ទឹកស្លែក្តោបពណ៌ស្វាយ គឺជាអង្គធាតុចង្អុលពណ៌អាស៊ីត-បាស (ការផ្លាស់ប្តូរពណ៌អាស្រ័យលើកំរិត អាស៊ីត-បាស នៅក្នុងសូលុយស្យុង) ។ នៅក្នុងសូលុយស្យុងអាស៊ីតវាមានពណ៌ផ្កាឈូក នៅក្នុងទឹកវាមានពណ៌ខៀវស្វាយ និងនៅក្នុងសូលុយស្យុងបាសវាមានពណ៌បៃតង ឬលឿង ។

**ពិសោធន៍ទី ១៧ : ប្រតិកម្មអាស៊ីត បាស : NaOH និង HCl** សៀវភៅសិស្ស ទំព័រ ១៧៦,១៨៤

សៀវភៅសិស្ស ទំព័រ ១៧៦,១៨៤

គោលបំណង : សិស្សអាចពន្យល់ពីភាពការផ្លាស់ប្តូរលក្ខណៈរបស់សូលុយស្យុងពេលបន្ថែមសារធាតុផ្សេងចូល ដោយប្រើអង្គធាតុចង្អុរពណ៌(ពីអាស៊ីតទៅបាស)

សំភារៈនិង សារធាតុ:

- ដបប្លាស្ទិចកាត់មាត់មួយ
- ទឹក
- អង្គធាតុចង្អុលពណ៌ (ទឹកស្លែក្តោបពណ៌ស្វាយ)
- សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ៥ ម៉ូល
- អាស៊ីតក្លរីឌ្រិច (HCl)
- ស្លាបព្រាតូច

ដំណើរការពិសោធន៍:

១- ចាក់ទឹកចូលក្នុងដបកាត់មាត់មួយរហូតដល់គំនូសក្រិតទីមួយ ហើយបន្ថែមអាស៊ីតក្លរីឌ្រិច HCl (ទឹកលាងបង្គន់) រហូតដល់គំនូសក្រិតទីពីរ ។

២- បន្ថែមទឹកស្លែក្តោបពណ៌ស្វាយបួនស្លាបព្រាពេញៗ ចូលទៅក្នុងដបកាត់មាត់ខាងលើ ហើយកូរវា និង ពិនិត្យមើលពណ៌ ។

៣- ចាក់សូលុស្យុងសូដ្យូមអ៊ីដ្រុកស៊ីតដែលមានកំហាប់ ៥ ម៉ូល ចូលទៅក្នុងដបកាត់មាត់ដែលមានអាស៊ីតក្លរីឌ្រិច និង ទឹកស្លែ ក្តោបពណ៌ស្វាយ រហូតដល់ពណ៌សូលុយស្យុងអាស៊ីតប្រែជាពណ៌ សូលុយស្យុងបាស ។

**ចំណាំ** : ការប្រែប្រួលពណ៌នឹងកើតមាន នៅពេលដែលគេបន្ថែមសូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ចូល ។

សំនួរគន្លឹះ : តើមានអ្វីកើតឡើងចំពោះសូលុយស្យុងទឹកអាស៊ីតក្លរីឌ្រិចនៅពេលគេបន្ថែមសូលុយស្យុងបាស (សូដ្យូមអ៊ីដ្រុកស៊ីត)ចូល? តើអ្នកអាចសំគាល់បានដោយរបៀបណា?

អង្កេត :ពណ៌របស់ទឹកស្លែក្តោបពណ៌ស្វាយដែលនៅក្នុងសូលុយស្យុងអាស៊ីក្លរីឌ្រិច គឺ ពណ៌ផ្កាឈូក ។ ដោយសារ មានការបន្ថែមសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ពណ៌ផ្កាឈូកបានប្រែជាពណ៌បៃតងលឿង ។

**ពិសោធន៍ទី១៨ : ប្រតិកម្ម អាស៊ីត បាស : សូដ្យូមប៊ីកាបូណាត ($NaHCO_3$) និង ទឹកខ្មេះ (Vinegar)**

សៀវភៅសិស្ស ទំព័រ ១៨៤
សៀវភៅគ្រូ ទំព័រ ១០២

គោលបំណង : សិស្សអាចពន្យល់ពីភាពការផ្លាស់ប្តូរលក្ខណៈរបស់សូលុយស្យុងពេលបន្ថែមសារធាតុផ្សេងចូល ដោយប្រើអង្គធាតុចង្អុរពណ៌( ពីអាស៊ីតទៅបាស)

សំភារៈនិងសារធាតុ
- សូដ្យូមប៊ីកាបូណាត ($NaHCO_3$)
- ទឹកខ្មេះ
- ថង់ប្លាស្ទិចថ្លាធំមួយ
- ដបកាត់មាត់តូចមួយ
- ទឹកស្ពៃក្តោបពណ៌ស្វាយ
- ទៀន
- ស្លាបព្រា
- ឈើគូស

ដំណើរការពិសោធន៍:
១- ចាក់ទឹកខ្មេះប្រហែល 2 cm ទៅក្នុងដបកាត់មាត់តូចមួយ ហើយបន្ថែមទឹកស្ពៃក្តោបពណ៌ស្វាយចូលទៅក្នុងទឹកខ្មេះ ។
២- បន្ថែមម្សៅមេនំ ពីរស្លាព្រាចូលក្នុងគែមម្ខាងនៃថង់ប្លាស្ទិច
៣- បញ្ឈរដបកាត់មាត់ដែលមានទឹកខ្មេះឱ្យត្រង់នៅគែមម្ខាងទៀតនៃថង់
៤- ច្បូតខ្យល់ចេញឱ្យអស់ពីថង់ កាន់មាត់ថង់ខាងលើ ហើយ ក្រឡុកបញ្ចូលគ្នារវាងទឹកខ្មេះ និង ម្សៅមេនំ
៥- ដុតទៀន ហើយដាក់វាចូលទៅក្នុងមាត់ថង
៦- ស្ទាបសូលុយស្យុងពីខាងក្រៅថង ។

អង្កេត :ពណ៌ស្វាយខៀវនៃទឹកស្ពៃក្តោបបានប្រែពណ៌ជាក្រហមឈូក នៅពេលបន្ថែមទឹកខ្មេះចូល ។ នៅពេល ដែលទឹកខ្មេះត្រូវបានលាយជាមួយម្សៅមេនំនៅក្នុងថង់ប្លាស្ទិច មានពពុះកើតឡើង ហើយថង់ត្រូវបានបំប៉ោងដោយឧស្ម័ន យ៉ាងរហ័ស ពណ៌បានប្រែជាបៃតង ហើយសូលុយស្យុង ចាប់ផ្តើមចុះត្រជាក់ ។ នៅពេលគេបើកមាត់ ថង់ និង ផ្ទៀងភ្លើងទៀនក្បែរនោះ ឧស្ម័ន ដែលចេញពីក្នុងថង់បានពន្លត់ភ្លើងទៀននោះ ។

សំនួរគន្លឹះ : តើមានអ្វីកើតឡើងនៅពេលអ្នកបន្ថែមម្សៅសូដាទៅក្នុងទឹកខ្មេះ? តើអ្នកដឹងដោយរបៀបណា?

ការពន្យល់ : ប្រតិកម្មរវាងម្សៅមេនំ និង ទឹកខ្មេះ គឺជាប្រតិកម្មអាស៊ីត-បាស ដូចដែលបានបង្ហាញនៅពេល មានការប្រែប្រួលពណ៌ទឹកស្ពៃក្តោបពណ៌ស្វាយ ។ ឧស្ម័នដែលបានផលិត គឺជាឧស្ម័នមិនទ្រទ្រង់ចំហេះទេ ( កាបូនឌីអុកស៊ីត) ហើយ ល្បាយប្រតិកម្មចុះត្រជាក់ ( ជាប្រតិកម្មស្រូបកំដៅ) ។

**ប្រតិកម្មគីមី** $CH_3COOH + NaHCO_3 \rightarrow CH_3COONa + H_2O + CO_2$







**ពិសោធន៍ ទី ១៩ : កាល់ស្យូមអុកស៊ីត (CaO) និង ទឹក ($H_2O$) (ទឹកលាយជាមួយទឹក ស្ពៃក្តោបពណ៌ស្វាយ)**

គោលបំណង : សិស្សអាចអត្តសញ្ញាណសូលូយស្យុងបាស ឬអាស៊ីតដោយប្រើអង្គធាតុចង្អុរពណ៌។

សំភារៈនិងសារធាតុ:

**សៀវភៅសិស្ស ទំព័រ ១៨៤**

- កែវបេស៊ែរ
- ទឹក
- ទឹកស្ពៃក្តោបពណ៌ស្វាយ
- កាល់ស្យូមអុកស៊ីត

ដំណើរការពិសោធន៍: ១- ដាក់កាល់ស្យូមអុកស៊ីតចូលក្នុងកែវបេស៊ែរ

២- បន្ថែមទឹកស្ពៃក្តោបពណ៌ស្វាយទៅក្នុងកែវបេស៊ែរកាល់ស្យូមអុកស៊ីត



អង្កេត : ទឹកស្លែក្ដោបពណ៌ស្វាយប្រែជាពណ៌បៃតង

សំនួរគន្លឹះ : តើដសូលុយស្យុងមានពណ៌អ្វីពេលបន្ថែមអង្គធាតុចង្អុរពណ៌ (ទឹកស្លែក្ដោបស្វាយ) ទៅលើកំបោរ? តើអ្នកអាចប្រាប់បានទេថាសូលុយស្យុងដែលទទួលបានជាអាស៊ីត ឬបាស?

ការពន្យល់ : កាល់ស្យូមអុកស៊ីតមានប្រតិកម្មជាមួយទឹកបង្កើតបានជាអង្គធាតុមិនរលាយ ហៅថា កាល់ស្យូម អ៊ីដ្រុកស៊ីត [$(Ca(OH)_2$] ដែលសូលុយស្យុងដែលទទួលបាននេះជាបាស ព្រោះវាបំរែពណ៌ទឹកស្លែក្ដោបស្វាយទៅជាបៃតង-លឿង។

**ពិសោធន៍ទី២០ : ចំហេះ ស្ពាន់ធ័រ និង តេស្តស្ពាន់ធ័រឌីអុកស៊ីត**

គោលបំណង : សិស្សអាចបង្កើតអុកស៊ីតស្ពាន់ធ័រដោយសារចំហេះស្ពាន់ធ័រ ជាមួយអុកស៊ីសែនក្នុងខ្យល់ និងការតេស្តវាដោយប្រើទឹកអ៊ីយ៉ូត។

សៀវភៅសិស្ស ទំព័រ ១២៦

សំភារៈនិងសារធាតុ:

- ដបកាត់មាត់តូចចំនួនពីរ
- ឈើគូស
- ទឹកលាងរលួប ($I_2$)
- ទឹក
- ទឹកអុកស៊ីសែន ($H_2O_2$)

ដំណើរការពិសោធន៍:

១- ចាក់ទឹក 50 mL ទៅក្នុងដបជ័រ រឺ កែវ

២- បន្តក់ទឹកលាងរបួស $I_2$ ពីរ រឺ បី តំនក់ទៅក្នុងទឹក

៣- គ្របលែងដបជ័រ រឺ កែវ

៤- ដុតឈើគូស ៣ រឺ ៤ ដើម ហើយ ប្រមូលផ្សែងដំបូង ($SO_2$) ចូលទៅក្នុងកែវមួយផ្សេងទៀតដែគ្របពីលើកែវទី ១ យ៉ាងជិតដូចរូបខាងក្រោម

៥- គ្រឡុកល្បាយនៃទឹកលាងរបួស $I_2$ និង ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ រហូតដល់វាប្ដូរពណ៌ពី ពណ៌លឿងទៅគ្មានពណ៌ ។




អង្កេត :សូលុយស្យុងអ៊ីយ៉ូតប្រែជាគ្មានពណ៌បន្ទាប់ពីមានប្រតិកម្មជាមួយ $SO_2$ ដែលបានមកពីការដុតក្បាលឈើគូស ។

សំនួរគន្លឹះ : តើអ្នកអាចដឹងពីវត្តមាននៃស្ពាន់ធ័រឌីអុកស៊ីតនៅក្នុងកែវខាងលើទឹកអ៊ីយ៉ូតដោយសារអ្វី?

ការពន្យល់ :ពេលអ្នកគូសឈើគូសដែលមានស្ពាន់ធ័រ បង្កើតបានជាស្ពានលធ័រឌីអុកស៊ីតនៅក្នុងកែវខាងលើ ។ ដើម្បីដឹងថា ឧស្ម័នដែលកើតឡើងជាស្ពាន់ធ័រឌីអុកស៊ីតគឺអាស្រ័យទៅការបាត់ពណ៌របស់ទឹកអ៊ីយ៉ូតដែលប្រែពណ៌ពី លឿងទៅជាគ្មានពណ៌ ។ នេះបញ្ជាក់ពីការធ្វើអត្តសញ្ញាណស្ពាន់ធ័រឌីអុកស៊ីត ។ សូមមើលប្រតិកម្មខាងក្រោម :

$$S + O_2 \longrightarrow SO_2$$ ( បានមកពីការដុតក្បាលឈើគូស)

$$2H_2O_2 + I_2 + SO_2 \longrightarrow 2HI + H_2SO_4$$

($I_2$: ពណ៌លឿង; $2HI$: គ្មានពណ៌)

## ពិសោធន៍ទី ២១ : ការរៀបចំសូលុយស្យុងស៊ូត NaOH ៥ ម៉ូល( ការបង្ហាញរបស់គ្រូ)[២]

គោលបំណង : សិស្សអាចដឹងពីរបៀបរៀបចំសូលុយស្យុស៊ូតកំហាប់ ៥ ម៉ូល

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់ ។

សំភារៈនិងសារធាតុ :

- ស៊ូត NaOH
- កែវអ៊ែកឡែក ចំនុះ 500 mL
- ស្លាបព្រាមួយ

ដំណើរការពិសោធន៍ : ១- ដាក់ស៊ូត ១00ក្រាម ចូលក្នុងកែវអ៊ែកឡែន

២- បន្ថែមទឹករហូតដល់ចំនុះប្រហែល ៤00 mL ។ គ្រលេងថ្នមៗដើម្បីរំលាយស៊ូត

---

[2] ចំពោះការពិសោធនេះគឺគ្រូជាអ្នកធ្វើតែប៉ុននោះ ព្រោះវាអាចចំនាយពេលយូរ និង មានគ្រោះថ្នាក់

យកដៃស្ទាបដោយប្រុងប្រយ័ត្នព្រោះវាក្តៅ (ជាប្រតិកម្មបញ្ចេញកំដៅ) ។




**ពិសោធន៍ទី២២ : ការរំលាយ ស៊ូតកាត់**

មិនមានឯកសារយោងនៅក្នុងសៀវភៅអត្ថបទទេ ប៉ុន្តែវាសំខាន់ណាស់ដើម្បីឱ្យសិស្សយល់។

គោលបំណង : សិស្សអាចពន្យល់ពីលក្ខណៈនៃការរលាយរបស់ដុំស៊ូត ។

សំភារៈនិងសារធាតុ

- បំពង់សាក ទម្របំពង់សាក ដង្កៀបសំរាប់ចាប់បំពង់សាក
- ទឹក
- ក្រាមស៊ូត

ដំណើរការពិសោធន៍ : ១- ដាក់ស៊ូតបន្តិចចូលក្នុងបំពង់សាក

២- បន្ថែមទឹក ៣ សង់ទីម៉ែត្រ ហើយក្រលេងវាថ្នមៗ

អង្កេត :បំពង់សាកឡើងក្តៅ

សំនួរគន្លឹះ : នៅពេលដែលដុំស៊ូតរលាយក្នុងទឹក តើមានអ្វីកើតឡើង? ក្តៅ ឬត្រជាក់?

ការពន្យល់ : ជាធម្មតា អង្គធាតុរឹងមួយចំនួនឡើងកំដៅ រឺ ចុះត្រជាក់ នៅពេលគេរំលាយវា។ ចំពោះដុំស៊ូត នៅពេលរលាយក្នុងទឹកគឺវាបញ្ចេញយ៉ាងខ្លាំង។

**ពិសោធន៍ទី ២៣ : កាល់ស្យូមកាបូណាត (សំបកពងមាន់) ជាមួយអាស៊ីតក្លរីឌ្រិច HCl (ទឹកលាងបង្គន់)**

គោលបំណង : សិស្សអាចអត្តសញ្ញាណពីឧស្ម័នដែលបានពីប្រតិកម្មរវាងសំបកស៊ុត និង HCl

សំភារៈនិងសារធាតុ:

សៀវភៅសិស្ស ទំព័រ ១៨៤
សៀវភៅគ្រូ ទំព័រ ១០២

- សំបកពងមាន់
- អាស៊ីតក្លរីឌ្រិច

- កែវអែកឡែន ចំនុះ ១០០ មីលីលីត្រ
- ថង់ប្លាស្ទិច

ដំណើរការពិសោធន៍ : ១- បំបែកសំបកពងមាន់ឱ្យទៅជាបំនែកតូចៗ បន្ទាប់មកដាក់វាចូលក្នុងកែវ

២- ចាក់អាស៊ីតក្លរីឌ្រិច ( ប្រហែល ១០-២០ mL ) ចូលក្នុងកែវ

៣- យកថង់ប្លាស្ទិចគ្របពីលើមាត់កែវ

៤- បន្ទាប់ពីថង់បានផ្ទុកឧស្ម័ន យើងចាក់ទឹកកំបោរថ្លាចូលទៅក្នុងថង់ដើម្បីតេស្តឧស្ម័ននោះ ។




អង្កេត :ពពុះកកើតឡើង ហើយថង់ប្លាស្ទិចឡើងប៉ោង ។

សំនួរគន្លឹះ : តើមានអ្វីកើតឡើងនៅពេលអ្នកចាក់អាស៊ីតក្លរីឌ្រិចទៅលើសំបកស៊ុត? តើអ្នកគិតថាឧស្ម័ននេះជាឧស្ម័នអ្វី? តើមានអ្វីមកបញ្ជាក់?

ការពន្យល់ :ពពុះមានន័យថា ឧស្ម័នបាបកកើតឡើងពីប្រតិកម្មរវាងសំបកស៊ុត និង HCl ហើយឧស្ម័នគឺជាមូលហេតុដែលធ្វើឱ្យថង់ប្លាស្ទិចប៉ោង និងទឹកកំបោរប្រែជាល្អក់បញ្ជាក់ថាឧស្ម័ននោះជា ឧស្ម័នកាបូនិច ។

សមីការតាងប្រតិកម្ម: $CaCO_3(s) + 2HCl\ (l) \rightarrow CaCl_2(aq) + CO_2\ (g) + H_2O\ (l)$

$Ca(OH)_2 + CO_2 \rightarrow CaCO_3\ (s) + H_2O\ (l)$

## សេចក្តីបន្ថែមទី ១: បញ្ជីទីកន្លែង និងតម្លៃសំភារៈ និងសារធាតុ ពិសោធន៍វិទ្យាសាស្ត្រ

| ល.រ | ឈ្មោះសំភារៈ និង សារៈធាតុ | ចំនួន | តំលៃរាយ | អាស្រ័យដ្ឋាន |
|---|---|---|---|---|
| ១ | សូដ្យូមអ៊ីដ្រុកស៊ីត (NaOH) | ១ Kg | ៤០០០ រ | តូបលេខ២១ ផ្សារអូរឬស្សី ភ្នំពេញ |
| ២ | ទង់ដែងស៊ុលផាត ($CuSO_4$) | ១ Kg | ១៥០០០ រ | តូបលេខ២១ ផ្សារអូរងឬស្សី ភ្នំពេញ |
| ៣ | ទឹកអុកស៊ីសែននេ ($H_2O_2$) | ១យូរ | ៣៥០០ រ | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ៤ | ទឹកអ៊ីយ៉ូត | ១យូរ | ៨០០០ រ | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ៥ | ចង្កៀងអាកុល | ១ | ១ ដូល្លា | ផ្ទះលេខ ៥ Eo ផ្លូវ១៧៣ សង្កាត់អូឡាំពិច, ផ្សារអូឡាំពិច, ភ្នំពេញ |
| ៦ | អាកុល | ១យូរ | ២.៨០ ដូល្លា | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ៧ | បំពង់សាក | ១ | ៣០០រ | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ៨ | កែវបេស៊ែ (100mL) | ១ | ១,៥ ដូល្លា | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |

| | | | | |
|---|---|---|---|---|
| ៩ | កែវអ៊ែកឡែនតូច (100mL) | ១ | ១,៥ ដូល្លា | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ១០ | កែវអ៊ែកឡែនធំ (500mL) | ១ | ២,៥ ដូល្លា | ក្បែររបងវត្តមហាមន្ត្រី សង្កាត់អូរឡាំពិច ផ្លូវ១៧៣ ភ្នំពេញ |
| ១១ | ម្សៅមេនំ ($NaHCO_3$) | ១ប្រអប់ | ១,៣០ដូល្លា | ផ្សារទំនើប ឡាក់គី ភ្នំពេញ |
| ១២ | ល័ក្ខ | ១ | ៣០០៛ | តូបលេខ២១ ផ្សារអូរឫស្សី ភ្នំពេញ |

## សេចក្តីបន្ថែមទី ២ បញ្ជីតម្លៃ និងចំនួនសំភារៈពិសោធន៍សំរាប់ការស្នើសុំ

| ល,រ | ឧបករណ៍ ឬសារធាតុ | បរិមាណ | តម្លៃរាយ ( US $ ) | សរុប (US $) |
|---|---|---|---|---|
| 1 | បំពង់សាក (Test tubes) | 20 | $ 0.075 | $ 1.50 |
| 2 | បំពង់សាកតូច (Test tubes) | 20 | $ 0.015 | $ 0.30 |
| 3 | កែវបេស៊ែរ ១០០ ម.ល ( Beakers(100mL)) | 3 | $ 1.50 | $ 4.50 |
| 4 | កែវបេស៊ែរ ៥០០ ម.ល ( Beakers(500mL)) | 3 | $ 2.50 | $ 7.50 |
| 5 | កែវអ៊ែកឡែន ៥០០ ម.ល (Erlenmeyer Flask (500mL)) | 3 | $ 2.50 | $ 7.50 |
| 6 | កែវអ៊ែកឡែន ១០០ ម.ល (Erlenmeyer Flask (100mL)) | 3 | $ 1.50 | $ 4.50 |
| 7 | ស្លាប់ | 3 | $ 2.00 | $ 6.00 |
| 8 | ដញ្ញីង | 3 | $ 2.00 | $ 6.00 |
| 9 | ដបមានក្បាលវ៉ាល់ | 3 | $ 0.63 | $ 3.78 |
| 10 | ឈើគូស | 1 កញ្ចប់ | $ 0.50 | $ 0.50 |
| 11 | ដបដាក់ល័ក្ខ | 10 | $ 1.00 | $ 1.00 |
| 12 | ថង់ប្លាស្ទិចធំ | 100g | $ 0.25 | $ 0.25 |
| 13 | ថង់ប្លាស្ទិចតូច | 100g | $ 0.25 | $ 0.25 |

| | | | | |
|---|---|---|---|---|
| 14 | ដង្កៀបតូច | 6 | $ 0.25 | $ 1.50 |
| 15 | ដង្កៀបធំ | 6 | $ 0.38 | $ 2.28 |
| 16 | កែវ | 1 ប្រអប់ | $ 2.00 | $ 2.00 |
| 17 | កន្ត្រៃ | 6 | $ 0.38 | $ 2.28 |
| 18 | ទឹកអុកស៊ីសែន $H_2O_2$ | 2 យួរ | $ 0.9 | $ 1.8 |
| 19 | អាល់កុល (97%) | 2 ដប | $ 0.625 | $ 1.25 |
| 20 | ទឹកអ៊ីយ៉ូត | 6 ដប | $ 1.00 | $ 1.00 |
| 21 | ចានជ័រធំ | 6 | $ 0.375 | $ 2.25 |
| 22 | ក្រដាសអាលុយមីញ៉ូម | 1 ដុំ | $ 1.20 | $ 1.20 |
| 23 | ម្សៅមេនំ Baking Soda | 1 កញ្ចប់ | $ 1.30 | $ 1.30 |
| 24 | ដីស | 1 ប្រអប់ | $ 0.10 | $ 0.10 |
| 25 | ចង្កៀងអាល់កុល | 6 | $ 1.00 | $ 6.00 |
| 26 | ស្បៃរុំរបួស | 1 កញ្ចប់ | $ 0.15 | $ 0.15 |
| 27 | ប៉េងប៉ោង | 1 កញ្ចប់ | $ 2.00 | $ 2.00 |
| 28 | ទឹកលាងបង្គន់ (Supper OK) | 1 ដប | $ 1.13 | $ 1.13 |
| 29 | ប្រេងឆា | 1 ដប | $ 1.33 | $ 1.33 |
| 31 | ទុយយោ | 1 កញ្ចប់ | $ 0.375 | $ 0.375 |
| 32 | ទៀនតូច | 1 កញ្ចប់ | $ 0.25 | $ 0.25 |
| 33 | ទៀនធំ | 3 កញ្ចប់ | $ 0.50 | $ 0.50 |
| 34 | ម្សៅពោត | 1 កញ្ចប់ | $ 1.45 | $ 1.45 |
| 35 | ទឹកខ្មេះ | 6 ដប | $ 0.375 | $ 2.25 |
| 36 | សាច់ជូរខៀវ ($CuSO_4$) | 1Kg | $ 3.75 | $ 3.75 |
| 37 | មេសាប៊ូ NaOH | 1Kg | $ 1.00 | $ 1.00 |
| 38 | សំលី | 2 កញ្ចប់ | $ 0.25 | $ 0.50 |
| 39 | ចង្កឹះឬស្សី | ½ កញ្ចប់ | $ 0.60 | $ 0.60 |
| 40 | សាប៊ូលាងចាន | 1 ដប | $ 0.60 | $ 0.60 |
| 41 | ល័ក្ត | 9 កញ្ចប់ | $ 0.075 | $ 0.675 |

| | | | | |
|---|---|---|---|---|
| 42 | អំបិល | 2 កញ្ចប់ | $ 0.375 | $ 0.75 |
| 43 | បន្ទាត់ | 2 កញ្ចប់ | $ 1.10 | $ 2.20 |
| 44 | ទម្រជើងបី | 3 | $ 2.00 | $ 6.00 |
| 45 | ទម្របំពង់សាក | 3 | $ 1.00 | $ 3.00 |
| 46 | បន្ទាត់ | 1 | $ 2.00 | $ 3.00 |
| | | | **សរុប** | $ 98.05 |

## សេចក្តីបន្ថែមទី ៣: ផ្លាកសញ្ញាសម្រាប់គ្រូរៀបចំសំភារៈពិសោធន៍

ចំនាំ : គ្រូជាច្រើនពេលបានទទួលសំភារៈពិសោធន៏វិទ្យាសាស្ត្រសម្រាប់ថ្នាក់រៀនហើយលែងប្រើដោយសារតែមិនបានបិតផ្លាក សញ្ញា និងរៀបចំ ។ ផតចំលងផ្លាកសញ្ញាខាងក្រោមអាចជួយក្នុងការរៀបចំសំភារៈថ្នាក់រៀន ឬបន្ទប់ពិសោធន៏របស់អ្នកបាន ។

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ប៉េងប៉ោងក្នុងដប**
Balloon in Bottle

**ពណ៌វិធី**
Chalk Chromatography

**ពណ៌វិធី**
Chalk Chromatography

**ពណ៌វិធី**
Chalk Chromatography

**ពណ៌វិធី**
Chalk Chromatography

**ពណ៌វិធី**
Chalk Chromatography

**ពណ៌វិធី**
Chalk Chromatography

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ទឹកស្ពៃក្តោបស្វាយ**
Red cabbage juice

**ខ្លាញ់គោ**
Motorcycle grease

**កំបោរ CaO**

**កំបោរ CaO**

**កំបោរ CaO**

**កំបោរ CaO**

**កំបោរ CaO**

**កំបោរ CaO**

**ដង់ស៊ីតេ ទឹកអំបិល**
Density (salt water)

**ដង់ស៊ីតេ**
**Density A &W**

**ដង់ស៊ីតេ**
**Density A &W**

**ដង់ស៊ីតេ ទឹក**
Density (water)

**រលកទឹកក្នុងដប**
Wave in Bottle

**រលកទឹកក្នុងដប**
Wave in Bottle

**រលកទឹកក្នុងដប**
Wave in Bottle

**រលកទឹកក្នុងដប**
Wave in Bottle

**រលកទឹកក្នុងដប**
Wave in Bottle

**រលកទឹកក្នុងដប**
Wave in Bottle

| | | |
|---|---|---|
| អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) |
| អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឥដ្ឋ) Solid & Liquid (brick) |
| អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) |
| អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) | អង្គធាតុរឹង និង អង្គធាតុរាវ (ដុំឈើ) Solid & Liquid (wood) |
| ស៊ុតក្នុងទឹកខ្មេះ(អូស្មូស) Egg in Vinegar(Osmosis) | ស៊ុតក្នុងទឹកខ្មេះ(អូស្មូស) Egg in Vinegar(Osmosis) | ស៊ុតក្នុងទឹកខ្មេះ(អូស្មូស) Egg in Vinegar(Osmosis) |
| ស៊ុតក្នុងទឹកខ្មេះ(អូស្មូស) Egg in Vinegar(Osmosis) | ស៊ុតក្នុងទឹកខ្មេះ(អូស្មូស) Egg in Vinegar(Osmosis) | |

| | | |
|---|---|---|
| ដបទេវមន្ត Pushes & Pulls bottle | ដបទេវមន្ត Pushes & Pulls bottle | ដបទេវមន្ត Pushes & Pulls bottle |
| ដបទេវមន្ត Pushes & Pulls bottle | ដបទេវមន្ត Pushes & Pulls bottle | ដបទេវមន្ត Pushes & Pulls bottle |